វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សា
ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម
និងជនបទ

វិទ្យាស្ថាន
ស្រាវជ្រាវគោលនយោបាយ
ស្បៀងអន្តរជាតិ

# របាយការណ៍កិច្ចប្រជុំតុមូលស្តីពី
# សន្តិសុខស្បៀង និងគោលនយោបាយកសិកម្មកម្ពុជា




សហការបោះពុម្ពផ្សាយដោយ

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (វបសអ/CDRI)

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** (CARD)

**វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ** (IFPRI)

ឧបត្ថម្ភដោយ

**ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ** (USAID)

USAID
FROM THE AMERICAN PEOPLE

# របាយការណ៍កិច្ចប្រជុំតុមូលស្តីពី
# សន្តិសុខស្បៀង និង
# គោលនយោបាយកសិកម្មកម្ពុជា

សហការបោះពុម្ពផ្សាយដោយ

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** ( **វបសអ**/CDRI )

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** ( CARD )

**វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ** ( IFPRI )

ឧបត្ថម្ភដោយ

**ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ** ( USAID )

រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១១

**របាយការណ៍កិច្ចប្រជុំតុមូលស្តីពី**
**សន្តិសុខស្បៀង និងគោលនយោបាយកសិកម្មកម្ពុជា**
**(Cambodia Food Security and Agricultural Policy - Roundtable Proceedings)**

រៀបចំដោយ
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/ CDRI) ក្នុងកិច្ចសហការជាដៃគូជាមួយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និង វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ រាជធានីភ្នំពេញ

**វិទ្យាស្ថាន** CDRI
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោក
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ឹង សុជាតិ និង អ៊ុំ ចាន់ថា
បោះពុម្ពនៅប្រទេសកម្ពុជាដោយសហគ្រាស ធី អែន អេស

# មាតិកា


**បញ្ជីអក្សរកាត់** ........ v
**កម្មវិធី** ........ vii
**ខ្លឹមសារសង្ខេប** ........ 1
**សេចក្តីផ្តើម** ........ 3
**យុទ្ធសាស្ត្រ និងគោលនយោបាយវិស័យកសិកម្ម** ........ 4
យុទ្ធសាស្ត្រ និងគោលនយោបាយវិស័យកសិកម្មដែលមានស្រាប់ ........ 4
ដំណាំស្រូវ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យផ្សេងៗ ........ 5
ការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ និងចន្លោះខ្វះខាតខាងចំណេះដឹង ........ 6
សំណួរគួរស្រាវជ្រាវនាពេលអនាគត ........ 7
**សន្តិសុខស្បៀង អាហារូបត្ថម្ភ និង ការគាំពារសង្គម** ........ 11
ផលសម្រេចថ្មីៗក្នុងការកែលម្អអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ........ 11
ចន្លោះខ្វះខាតខាងចំណេះដឹង និងវិស័យសម្រាប់ការស្រាវជ្រាវទៅថ្ងៃមុខ ........ 12
**ធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ** ........ 14
ហេតុអ្វីបានជាអភិបាលកិច្ចធនធានធម្មជាតិមានសារៈសំខាន់ ........ 14
យុទ្ធសាស្ត្រចំពោះអភិបាលកិច្ចធនធានធម្មជាតិ ........ 15
ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ........ 16
ការខ្វះចន្លោះផ្នែកចំណេះដឹង ........ 18
អាទិភាពសម្រាប់ការស្រាវជ្រាវនាពេលអនាគត និងការកសាងសមត្ថភាព ........ 19
**សន្និដ្ឋាន** ........ 21
**ឧបសម្ព័ន្ធ** ........ 24
ឧបសម្ព័ន្ធ ១. ឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំតុមូល ........ 24
ឧបសម្ព័ន្ធ ២. បទបង្ហាញនៅក្នុងកិច្ចប្រជុំតុមូល ........ 24
ឧបសម្ព័ន្ធ ៣. បញ្ជីអ្នកចូលរួម ........ 24

## បញ្ជីអ្នករួមចំណែក

### សុន្ទរកថាស្វាគមន៍

- លោក Larry Strange នាយកប្រតិបត្តិនៃ CDRI
- ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន អនុប្រធានអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បណ្ឌិត Blake D Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI

### ប្រធានបទទី ១៖ យុទ្ធសាស្ត្រ និងគោលនយោបាយកសិកម្ម

- លោក ច័ន្ទ សុផល ប្រធានសមាគមសេដ្ឋកិច្ចកម្ពុជា
- បណ្ឌិត ថេង វុទ្ធី អ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃ CDRI
- បណ្ឌិត Bingxin Yu អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI
- ឯកឧត្តម សាន វណ្ណាទី អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រធានបទទី ២៖ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការការពារខាងសង្គមកិច្ច

- ឯកឧត្តម ងី ចាន់ផល រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និង អនុប្រធានទី២ នៃ CARD
- បណ្ឌិត Olivier Ecker អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI
- លោក គឹម សុធន អ្នកស្រាវជ្រាវ នៃ CDRI
- ឯកឧត្តម បណ្ឌិត សាន វឌ្ឍនា អគ្គលេខាធិការរងនៃ CARD

### ប្រធានបទ ៣៖ ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ

- លោកស្រី ចំរើន មុទិតា អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍ជនបទ នៃធនាគារពិភពលោក (បញ្ជាក់តាមក្រោយ)
- បណ្ឌិត Timothy S. Thomas អ្នកស្រាវជ្រាវនៃ IFPRI
- បណ្ឌិត Blake D. Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃ IFPRI
- បណ្ឌិត ទិន ពន្លក នៃ លេខាធិការដ្ឋានគណៈកម្មាធិការបម្រែបម្រួលអាកាសធាតុជាតិ និងជានាយកផ្នែកបម្រែបម្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន

### សុន្ទរកថាបូកសរុប៖ ចន្លោះខ្វះខាតគោលនយោបាយ និងផ្លូវឈានទៅមុខ

- បណ្ឌិត Xinshen Diao អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI (៥នាទី)
- ឯកឧត្តម  តាវ សេងហួរ ទេសរដ្ឋមន្ត្រី និង អនុប្រធានទី២ នៃ CARD

**កិច្ចប្រជុំតុមូលបូកសរុបពី**

**គោលនយោបាយកសិកម្ម និង សន្តិសុខស្បៀងនៅកម្ពុជា**

ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០១០ នៅសណ្ឋាគារភ្នំពេញ

កិច្ចសហការរវាង

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** (CARD)

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI)

**វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ** (IFPRI)

ក្រោមជំនួយឧបត្ថម្ភពី USAID

**<u>វត្ថុបំណង</u>**

(១) បង្ហាញពីស្ថានភាពបច្ចុប្បន្ននៃចំណេះដឹងក្នុងវិស័យគោលនយោបាយសំខាន់ៗ ទាក់ទងនឹងសន្តិសុខស្បៀង រាប់បញ្ចូលទាំងចន្លោះខ្វះខាតចំណេះដឹងនាពេលសព្វថ្ងៃ ។

(២) កំណត់អាទិភាពនានា សម្រាប់កិច្ចសហការណ៍ទៅថ្ងៃអនាគត ស្តីពីសមត្ថភាព និងការស្រាវជ្រាវផ្តោតលើគោលនយោបាយ ។

**<u>លទ្ធផលគ្រោងទុក</u>**

(១) ដៃគូសហការមានការយល់ដឹងកាន់តែប្រសើរពី អាទិភាពនៃគំនិតផ្តួចផ្តើមសហការដែលកំពុងផុសឡើងក្នុងការស្រាវជ្រាវផ្តោតលើគោលនយោបាយ និងការកសាងសមត្ថភាព ដើម្បីដោះស្រាយបញ្ហាប្រឈម នៃសន្តិសុខស្បៀងនៅកម្ពុជា ។

(២) ដៃគូសហការណ៍មានការយល់ដឹងកាន់តែប្រសើរពីអត្ថប្រយោជន៍ និងតម្រូវការនៃអ្នកពាក់ព័ន្ធផ្សេងៗ ដែលជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវកំណត់នូវជំហានបន្ទាប់ៗទៀតក្នុងកិច្ចសហការណ៍គ្នា ។

**កម្មវិធី**

08:00-08:30 ការចុះឈ្មោះ និងការអញ្ជើញអង្គុយតាមកន្លែង

08:30-09:00 សុន្ទរកថាស្វាគមន៍

**លោក** Larry Strange នាយកប្រតិបត្តិនៃ CDRI

**ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន** អនុប្រធានអចិន្ត្រៃយ៍ នៃឧត្តមក្រុមប្រឹក្សា សេដ្ឋកិច្ចជាតិ និង រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បរិបទ វត្ថុបំណង និង លទ្ធផលគ្រោងទុក នៃកិច្ចប្រជុំតុមូល

បណ្ឌិត Blake D Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI

09:00-12:00 ការធ្វើបទបង្ហាញ

09:00-09:50 **ប្រធានបទទី ១៖ យុទ្ធសាស្ត្រ និងគោលនយោបាយកសិកម្ម**

អ្នកសម្របសម្រួល៖ **លោក ច័ន្ទ សុផល** ប្រធានសមាគមសេដ្ឋកិច្ចកម្ពុជា

១. គោលនយោបាយកសិកម្ម និង ការស្រាវជ្រាវគោលនយោបាយ (១៥នាទី)
វាគ្មិន៖ **បណ្ឌិត ថេង វុទ្ធី** អ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃ CDRI
២. គោលនយោបាយកសិកម្ម៖ ជម្រើសអភិវឌ្ឍន៍នាពេលអនាគត សម្រាប់វិស័យស្រូវ (១៥នាទី)
វាគ្មិន៖ **បណ្ឌិត** Bingxin Yu អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI
វាគ្មិនបំផុសការពិភាក្សា៖ **ឯកឧត្តម សាន វណ្ណទី** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៥នាទី)

សំណួរស្នើការបំភ្លឺ (១៥នាទី)

09:50-10:05 សំរាកពិសាភេសជ្ជៈ

10:10-11:00 **ប្រធានបទទី ២៖ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការការពារខាងសង្គមកិច្ច**

អ្នកសម្របសម្រួល៖ **ឯកឧត្តម ងី ចាន់ផល** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និង អនុប្រធានទី២ នៃ CARD

១. សន្តិសុខស្បៀង និង អាហារូបត្ថម្ភនៅកម្ពុជា៖ លំនាំ និងមធ្យោបាយ
វាគ្មិន៖ **បណ្ឌិត** Olivier Ecker អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI
២. ចម្រើសគោលនយោបាយសំរាប់ក្រុមជនងាយរងគ្រោះ ៖ កំណើនប្រាក់ចំណូល និង ការការពារខាងសង្គមកិច្ច (១៥នាទី)
វាគ្មិន៖ **លោក គឹម សុធន** អ្នកស្រាវជ្រាវ នៃ CDRI
វាគ្មិនបំផុសការពិភាក្សា៖ **ឯកឧត្តម បណ្ឌិត សាន វឌ្ឍនា** អគ្គលេខាធិការរងនៃ CARD (៥នាទី)

សំណួរស្នើការបំភ្លឺ (១៥នាទី)

11:00-11:50 **ប្រធានបទ ៣៖ ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ**

អ្នកសម្របសម្រួល៖ **លោកស្រី ចំរើន មុទិតា** អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍ជនបទ នៃធនាគារពិភពលោក

១. សន្តិសុខស្បៀង និងបម្រែបម្រួលអាកាសធាតុ ដល់ឆ្នាំ២០៥០៖ ប្រទេសកម្ពុជា (១៥នាទី)
វាគ្មិន៖ **បណ្ឌិត** Timothy S. Thomas អ្នកស្រាវជ្រាវនៃ IFPRI
២. អភិបាលកិច្ចធនធានធម្មជាតិ និងសន្តិសុខស្បៀងនៅកម្ពុជា (១៥នាទី)
វាគ្មិន៖ **បណ្ឌិត** Blake D. Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃ IFPRI
វាគ្មិនបំផុសការពិភាក្សា៖ **បណ្ឌិត ទិន ពន្លក នៃ** លេខាធិការដ្ឋានគណៈកម្មាធិការបម្រែបម្រួល អាកាសធាតុជាតិ និងជានាយកផ្នែកបម្រែបម្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន (៥នាទី)

សំណួរស្នើការបំភ្លឺ (១៥នាទី)

12:00-13:00 ពិសារអាហារថ្ងៃត្រង់

13:00-15:00 ការបំបែកជាក្រុមពិភាក្សា ដោយមានអ្នកសម្របសម្រួលតាមក្រុម
អ្នកចូលរួមអាចចូលពិភាក្សាក្នុងក្រុមការងារមួយ ហើយក្រុមនីមួយៗត្រូវជ្រើសរើស
អ្នកតំណាងក្រុមម្នាក់ ដើម្បីរាយការណ៍ជូនការប្រជុំពេញអង្គ ។ ក្រុមការងារនីមួយៗត្រូវកំណត់នូវ
កង្វះខាតចំណេះដឹងសំខាន់ៗ ចំនួន ៥ និង អាទិភាពទៅអនាគតចំនួន ៥ សម្រាប់
ការស្រាវជ្រាវផ្តោតលើគោលនយោបាយ និង ការកសាងសមត្ថភាព។

**ក្រុម ១៖ យុទ្ធសាស្ត្រ និងគោលនយោបាយកសិកម្ម**
អ្នកសម្របសម្រួល៖ **ឯកឧត្តម សាន វណ្ណទី** អនុរដ្ឋលេខាធិការ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក្រុម ២៖ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការការពារខាងសង្គមកិច្ច**
អ្នកសម្របសម្រួល៖ **ឯកឧត្តម បណ្ឌិត សាន វឌ្ឍនា** អគ្គលេខាធិការរងនៃ CARD

**ក្រុម ៣៖ ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ**
អ្នកសម្របសម្រួល៖ **បណ្ឌិត ទិន ពន្លក នៃ** លេខាធិការដ្ឋានគណៈកម្មាធិការ
បម្រែបម្រួលអាកាសធាតុជាតិ និងជានាយកផ្នែកបម្រែបម្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន

15:00-15:15 សំរាកពិសាភេសជ្ជៈ

15:15-17:00 របាយការណ៍ពីក្រុមការងារនានា ស្តីពី កង្វះខាតចំណេះដឹង និងអាទិភាពខាង គោលនយោបាយ
និងការកសាងសមត្ថភាព (៥នាទីសម្រាប់ក្រុមមួយៗ)
ការពិភាក្សាពីកង្វះខាតផ្សេងៗ និងអាទិភាពនានា ក្នុងការប្រជុំពេញអង្គ
អ្នកសម្របសម្រួល៖ **បណ្ឌិត** Blake D. Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI

17:00-17:30 សុន្ទរកថាបូកសរុប៖ ចន្លោះខ្វះខាតគោលនយោបាយ និងផ្លូវឈានទៅមុខ
វាគ្មិន៖ **បណ្ឌិត** Xinshen Diao អ្នកស្រាវជ្រាវជាន់ខ្ពស់នៃ IFPRI
វាគ្មិន៖ **ឯកឧត្តម បណ្ឌិត តាវ សេងហួរ** ទេសរដ្ឋមន្ត្រី និង អនុប្រធានទី១ នៃ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍
វិស័យកសិកម្ម និងជនបទ (CARD)

## ខ្លឹមសារសង្ខេប

កំណត់ត្រាកិច្ចប្រជុំនេះ បូកសរុបលទ្ធផលនៃកិច្ចប្រជុំតុមូល រៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) និង វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងអនុសាសន៍នានាបានពីការពិភាក្សាតាមក្រុម នៅក្នុងកិច្ចប្រជុំតុមូលអំពីសន្តិសុខស្បៀង និងគោលនយោបាយកសិកម្មដែលធ្វើឡើងនៅទីក្រុងភ្នំពេញ នៅខែវិច្ឆិកា ឆ្នាំ២០១០។ អង្គប្រជុំ ក៏បានស្នើឲ្យផ្តោតការយកចិត្តទុកដាក់លើអាទិភាពនានាដូចខាងក្រោមនេះ នៅក្នុងការស្រាវជ្រាវគោលនយោបាយ និងការកសាងសមត្ថភាពក្នុងពេលអនាគតដ៏ខ្លីខាងមុខ៖

១. **ការគិតគូរឡើងវិញពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជានៅក្នុងផលិតកម្មស្រូវ។** ការងារនេះជួយកំណត់នូវមាគ៌ាផ្សេងៗដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារស្រូវអង្ករអន្តរជាតិ និងការគិតគូរពីកម្លាំងគួបគ្នា និងផលចំណេញធៀបគ្នារវាងគោលដៅអភិវឌ្ឍន៍ខុសៗគ្នាក្នុងវិស័យស្រូវអង្ករ ។ តម្រូវការចាំបាច់ធ្វើការវាយតម្លៃពីឥទ្ធិពលនៃគោលនយោបាយរបស់រដ្ឋាភិបាលសម្រាប់គាំទ្រវិស័យកសិកម្ម និងដំណាំជាក់លាក់មួយចំនួន មានជាអាទិ៍ ការវាយតម្លៃពីចំណាយ និងផលចំណេញនៃវិនិយោគសាធារណៈនៅក្នុងផែនការផ្សេងៗសម្រាប់អភិវឌ្ឍន៍ដំណាំស្រូវ ។ ម្យ៉ាងទៀត ក្នុងការស្រាវជ្រាវពីមាគ៌ានានាសម្រាប់អភិវឌ្ឍន៍វិស័យស្រូវអង្ករ គេត្រូវតែពិចារណាពីផលប៉ះពាល់នៃយុទ្ធសាស្ត្រខុសៗគ្នាសម្រាប់អភិវឌ្ឍន៍វិស័យស្រូវអង្ករនេះទៅលើភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅកម្រិតគ្រួសារ កម្រិតតំបន់ និងកម្រិតជាតិ ។

២. **ការយល់ដឹងពីតម្រូវការទីផ្សារ ដោយកំណត់ឲ្យបាននូវទីផ្សារសម្រាប់នាំចេញស្រូវអង្ករនាពេលបច្ចុប្បន្ន និងទៅអនាគត។** ត្រូវមានការស្រាវជ្រាវស៊ីជម្រៅ ដើម្បីញែកទីផ្សារផ្សេងៗឲ្យច្បាស់ ក្នុងនេះមានទាំងការពង្រីកទីផ្សារមានស្រាប់ និងការស្វែងរកទីផ្សារថ្មីនិងទីផ្សារពិសេសៗ ។ ការសិក្សាពីឧបសគ្គចំបងៗក្នុងការពង្រីក និងជ្រៀតចូលទីផ្សារ ព្រមទាំងគោលនយោបាយសម្រាប់ដោះស្រាយឧបសគ្គទាំងនេះ ក៏ត្រូវធ្វើឡើងដែរ ។ ការស្រាវជ្រាវក៏ត្រូវគូសបញ្ជាក់អំពីឥទ្ធិពលកាត់កងគ្នារវាងការនាំចេញអង្ករ នឹងការផ្គត់ផ្គង់ស្បៀងក្នុងប្រទេស ព្រមទាំង គោលនយោបាយត្រូវអនុវត្តដើម្បីរក្សាតុល្យភាពល្អរវាងតម្រូវការ និងការនាំចេញ ។

៣. **ការវាយតម្លៃពីជម្រើសផ្សេងៗសម្រាប់ពិពិធកម្មកសិកម្ម ដោយយកចិត្តទុកដាក់លើបទពិសោធន៍ និងមេរៀនដែលប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ធ្លាប់ឆ្លងកាត់។** ការស្រាវជ្រាវនេះ គួរផ្តោតលើទាំងផលិតកម្ម និងពិពិធកម្មការប្រើប្រាស់ ពីព្រោះបទពិសោធន៍នៅប្រទេសអាស៊ីអាគ្នេយ៍ឯទៀតៗបានបង្ហាញថា ពិពិធកម្មផលិតកម្មស្បៀងអាហារ អាចនាំឲ្យមានពិពិធកម្មការប្រើប្រាស់ដែលតែងជួយកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារនៅជនបទ ។ ទំនាក់ទំនងរវាងពិពិធកម្មផលិតកម្ម ពិពិធកម្មការប្រើប្រាស់ និងភាពប្រសើរឡើងនៃអាហារូបត្ថម្ភ គួរទទួលបានការសិក្សាលម្អិតជាងនេះទៅថ្ងៃអនាគត ។

៤. **ការវិភាគពីមូលហេតុនៃអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ។** ការវិភាគនេះជួយផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើលំនាំចំណាយលើម្ហូបអាហារ ការប្រើប្រាស់ស្បៀងអាហារ និងទម្លាប់ប្រើប្រាស់ស្បៀងអាហាររបស់ប្រជាជន ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ ផលប៉ះពាល់ខាងអាហារូបត្ថម្ភ និងសន្តិសុខស្បៀងនៃអន្តរាគមន៍ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដូចជា ការសាងសង់ទំនប់ទប់ស្ទឹងទន្លេជាដើម និងការប៉ះទង្គិចផ្សេងៗពីខាងក្រៅ ក៏គួរគិតគូរពិចារណាក្នុងការស្រាវជ្រាវដែរ។

៥. **ការបង្កើតជាវេទិកាមួយសម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យ ដើម្បីវាយតម្លៃកម្មវិធីគាំពារសង្គម ។** សកម្មភាពនេះត្រូវមានឧបករណ៍សមស្របជាក់ស្តែងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់ ដើម្បីពង្រីកកម្មវិធីបន្ថែមកម្មវិធីដែលមានជោគជ័យ រចនារៀបចំកម្មវិធីឲ្យបានកាន់តែប្រសើរឡើងទៀត និងផ្តោតអន្តរាគមន៍ឲ្យកាន់តែចំគោលដៅនាពេលអនាគត ។

៦. **ការវិភាគពីការគួបផ្សំគ្នា និងការកាត់កងគ្នារវាង គ្រោះថ្នាក់នៃហានិភ័យបម្រែបម្រួលអាកាសធាតុក្នុងរយៈពេលវែង និងបញ្ហាប្រឈមបច្ចុប្បន្នក្នុងការគ្រប់គ្រងធនធានធម្មជាតិ។** និន្នាការបម្រែបម្រួលអាកាសធាតុអាចបង្កជាហានិភ័យក្នុងរយៈពេលវែងក៏ពិតមែន ប៉ុន្តែការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនាពេលបច្ចុប្បន្ន វាចោទបញ្ហាបន្ទាន់ និងធ្ងន់ធ្ងរជាងដល់សន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រនៅកម្ពុជា ។ អន្តរាគមន៍ផ្នែកសន្តិសុខស្បៀងនៅកម្ពុជា ត្រូវឆ្លើយតបនឹងហានិភ័យ និងឱកាសល្អច្រើនបែបយ៉ាង ។ ទីភ្នាក់ងារជំនួយអន្តរជាតិ ដែលកំពុងផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការផ្តល់ហិរញ្ញប្បទានសម្រាប់ការសម្រាលឥទ្ធិពល និងការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុនោះ មិនគួរភ្លេចគិតគូរដល់បញ្ហាប្រឈមឯទៀតៗ ក្នុងការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនោះទេ ។ ជាការសមស្រប គួរមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយដែលផ្តោតលើហានិភ័យ និងឱកាស ដើម្បីបង្កើនលទ្ធភាពទប់ទល់ឧបសគ្គក្នុងការទ្រទ្រង់ជីវភាព និងលើកកម្ពស់សន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន ។

៧. **ការវិភាគពីផលចំណេញ និងហានិភ័យនៃសម្បទានខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មខ្នាតតូច។** សម្បទានដីសេដ្ឋកិច្ចខ្នាតធំ (ELCs) ដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម ជារឿយៗ មិនបានផ្តល់នូវផលប្រយោជន៍ដូចបានសន្យាដល់ប្រទេសកម្ពុជាឡើយ ។ រដ្ឋាភិបាលប្រទេសជាច្រើនកំពុងធ្វើការចរចាយ៉ាងសកម្មលើកិច្ចព្រមព្រៀងរយៈពេលវែង ដើម្បីទទួលបានដីកសិកម្មនៅកម្ពុជា ប៉ុន្តែគេមិនច្បាស់ទេថា តើកិច្ចព្រមព្រៀងបែបនេះអាចអនុវត្តយ៉ាងណាបាន ដោយពុំមានការជម្លៀសកសិករក្នុងមូលដ្ឋាន និងប្រជាជនដែលរស់នៅក្នុងព្រៃ ។ ការសិក្សាខ្លះ ក៏បានបង្ហាញផងដែរពីប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀតទាក់ទងនឹងសមធម៌ និងសន្តិសុខស្បៀង ។ ដូច្នេះ ត្រូវមានការវិភាគផ្តោតលើលទ្ធផលនៃសម្បទានខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ និងហានិភ័យនៃប្រព័ន្ធនីមួយៗ ភាពសមស្របរបស់វានៅក្នុងបរិបទខុសៗគ្នា និងប្រភេទនៃអន្តរាគមន៍ខាងគោលនយោបាយដែលត្រូវអនុវត្ត ។

៨. **ការស្រាវជ្រាវពីជម្រើសជាយុទ្ធសាស្ត្រផ្សេងៗ សម្រាប់គ្រប់គ្រងធនធានទ្រព្យរួម ដោយផ្តោតលើតួនាទីធនធានទាំងនោះសម្រាប់ជីវភាពនៅមូលដ្ឋាន។** ធនធានទ្រព្យរួម ដូចជា ព្រៃឈើ ដែននេសាទ តំបន់ដីសើម និងផ្ទៃទឹកនៅតាមតំបន់ឆ្នេរជាដើម មានសារៈសំខាន់បំផុតចំពោះជីវភាពប្រជាជនកម្ពុជាជាច្រើននៅតាមជនបទ។ ក្នុងទសវត្សរ៍កន្លងទៅនេះ មានការអនុវត្តកំណែទម្រង់ធំៗមួយចំនួន ហើយឥឡូវដល់ពេលធ្វើការវាយតម្លៃពី ការផ្លាស់ប្តូរផ្សេងៗដែលកំណែទម្រង់ទាំងនោះបានជះឥទ្ធិពលចំពោះជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅមូលដ្ឋាន និងពីវិធានការផ្សេងៗទៀតដែលត្រូវប្រើ ដើម្បីកែលម្អការអនុវត្តគោលនយោបាយដោះស្រាយចំណុចខ្វះខាត និងពង្រីកអត្ថប្រយោជន៍នៃកំណែទម្រង់ទាំងនោះ ។

៩. **ការស្រាវជ្រាវអំពីយុទ្ធសាស្ត្រផ្សេងៗទៀតសម្រាប់ជួយកសិករទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ។** ការងារនេះរួមមាន អនុសាសន៍សម្រាប់ការផ្លាស់ប្តូរគោលនយោបាយ និងអនុសាសន៍ស្តីពីដំណាំថ្មីៗ ប្រភេទរុក្ខជាតិសម្រាប់ដាំដុះ និងបច្ចេកទេសដាំដុះ។ ការស្រាវជ្រាវនេះ ក៏ត្រូវស្វែងរកមើលនូវចំណុចខ្វះខាតក្នុងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក្នុងស្ថានភាពកំពុងមានបម្រែបម្រួលអាកាសធាតុ និងអន្តរាគមន៍ផ្សេងៗទៀតដើម្បីពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។ ការស្រាវជ្រាវពីបម្រែបម្រួលអាកាសធាតុ មិនគួរមានតែអង្គការអន្តរជាតិជាអ្នកអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើវិនិយោគជាបន្ទាន់ លើការកសាងសមត្ថភាពស្ថាប័នក្នុងស្រុក ដើម្បីធ្វើការស្រាវជ្រាវប្រភេទនេះ ។ ម្យ៉ាងទៀត ក៏គួរមានចំណងទាក់ទងកាន់តែប្រសើរឡើងរវាងស្ថាប័នខាងបម្រែបម្រួលអាកាសធាតុរបស់រដ្ឋាភិបាល និងមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនានា និងគួរបង្កើនជំនួយគាំទ្រដល់ស្ថាប័នជាតិផងដែរ ។

## សេចក្តីផ្តើម

វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) ដោយសហការជាមួយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានធ្វើការសិក្សាបូកសរុបមួយនាពេលថ្មីៗដែលជាជំហានដំបូងនៃការប្រមើលពីកម្មវិធីរយៈពេលវែងមួយសម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពដើម្បីពង្រឹងសន្តិសុខស្បៀងនៅកម្ពុជា និងសមត្ថភាពជាតិក្នុងការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ។ ការសិក្សាបូកសរុបនេះ មានគោលបំណងកំណត់ពីការខ្វះចន្លោះផ្នែកចំណេះដឹង និងចង្អុលបង្ហាញនូវវិស័យអាទិភាពនានាសម្រាប់ការស្រាវជ្រាវគោលនយោបាយទៅថ្ងៃអនាគត ស្តីពីសន្តិសុខស្បៀង និងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា ដោយផ្អែកលើការវាយតម្លៃលើការសិក្សាពីមុនៗ និងទិន្នន័យមានស្រាប់ ព្រមទាំងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងអ្នកជំនាញការក្នុងស្រុក តាមរយៈការពិភាក្សាវែកញែកពីគោលនយោបាយសន្តិសុខស្បៀង និងកសិកម្មជាតិ ។ ការបូកសរុបនេះ សំដៅផ្តល់ជាព័ត៌មានគោលដល់រដ្ឋាភិបាល អង្គការអន្តរជាតិ សង្គមស៊ីវិល ក្រុមផ្តល់គំនិត សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ សម្រាប់ការធ្វើផែនការស្រាវជ្រាវ និងកសាងសមត្ថភាព ដើម្បីបំពេញចន្លោះខ្វះខាតខាងចំណេះដឹង ។

ដើម្បីបម្រើគោលបំណងធំទូលាយដូចខាងលើ ការសិក្សាបូកសរុបនេះ ក៏សំដៅសម្រេចឲ្យបាននូវគោលដៅជាក់លាក់ជាច្រើន ។ ទី១ គឺការជួយទ្រទ្រង់បេសកកម្មប្រចាំប្រទេសរបស់ USAID ក្នុងការតម្រង់ទិសវិនិយោគនាពេលអនាគតទៅលើវិស័យសន្តិសុខស្បៀង ជាពិសេសលើការស្រាវជ្រាវខាងគោលនយោបាយ និងការកសាងសមត្ថភាព ។ ទី២ គឺការផ្តល់វេទិកាសន្ទនាមួយសម្រាប់ឲ្យទីភ្នាក់ងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី អាចសម្របសម្រួលគ្នាលើការផ្តល់ជំនួយទ្រទ្រង់ក្នុងតំបន់នេះ ។ ទី៣ គឺការផ្តល់ជាមធ្យោបាយបង្កើតកិច្ចសហការសាកល្បងមួយរវាង IFPRI រដ្ឋាភិបាលកម្ពុជា និងស្ថាប័នស្រាវជ្រាវគោលនយោបាយមិនមែនរដ្ឋាភិបាល ។

បុគ្គលិកផ្នែកស្រាវជ្រាវរបស់ IFPRI និង CDRI បានរួមគ្នាចងក្រងឯកសារ ៦ច្បាប់ ស្តីពីលទ្ធផលស្រាវជ្រាវបានពីការសិក្សាបូកសរុប ។ ដោយផ្អែកលើលទ្ធផលស្រាវជ្រាវ ស្ថាប័នទាំងពីរបានរៀបចំកិច្ចប្រជុំតុមូលមួយ ស្តីពីគោលនយោបាយកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា នៅថ្ងៃទី៤ វិច្ឆិកា ២០១០ នៅរាជធានីភ្នំពេញ ដើម្បីបង្ហាញស្ថានភាពបច្ចុប្បន្ននៃចំណេះដឹងក្នុងវិស័យគោលនយោបាយសំខាន់ៗពាក់ព័ន្ធនឹងសន្តិសុខស្បៀង ដូចជា ការខ្វះចន្លោះផ្នែកចំណេះដឹងជាដើម និងកំណត់អាទិភាពសម្រាប់កិច្ចសហការទៅអនាគត លើការកសាងសមត្ថភាព និងការស្រាវជ្រាវខាងគោលនយោបាយ ។ កិច្ចប្រជុំនេះ ជាការផ្តួចផ្តើមគំនិតបង្កើតភាពជាដៃគូរវាង ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) វិទ្យាស្ថាន CDRI និង IFPRI ដោយទទួលបានមូលនិធិពី USAID ប្រចាំនៅកម្ពុជា ។ កិច្ចប្រជុំនេះជួយឲ្យដៃគូសហការនានា ទទួលបានការយល់ដឹងកាន់តែប្រសើរពីអាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការដោះស្រាយបញ្ហាចោទខាងសន្តិសុខស្បៀងនៅកម្ពុជា និងពីចំណាប់អារម្មណ៍និងតម្រូវការរបស់អ្នកពាក់ព័ន្ធនានា ដើម្បីទុកជាមូលដ្ឋានសម្រាប់កិច្ចសហការនៅជំហានបន្តបន្ទាប់ទៀត ។

អ្នកតំណាងជាង ៦០នាក់ មកពីអង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវក្នុងស្រុក និងដៃគូអភិវឌ្ឍន៍អន្តរជាតិ បានចូលរួមក្នុងកិច្ចប្រជុំនេះដែលចែកចេញជា ២វគ្គ ។ វគ្គទី១ នៅពេលព្រឹក តំណាងមកពី CARD, CDRI និង IFPRI ឡើងធ្វើបទបង្ហាញទាក់ទងនឹងប្រធានបទបី គឺ៖ (១) យុទ្ធសាស្ត្រ និងគោលនយោបាយកសិកម្ម (២) សន្តិសុខស្បៀង អាហារូបត្ថម្ភ និងកិច្ចគាំពារសង្គម និង (៣) ធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ ។ វគ្គនៅពេលរសៀល ជាការពិភាក្សាតាមក្រុមទាំងបីក្នុងពេលដំណាលគ្នា និងការពិភាក្សាពេញអង្គ ។ នៅពេលពិភាក្សាតាមក្រុមទាំងបី អ្នកចូលរួមបានបែងចែកគ្នាទៅតាមប្រធានបទទាំងបីនៃបទបង្ហាញក្នុងវគ្គនៅពេលព្រឹក ហើយពួកគេត្រូវផ្តោតលើប្រធានបទពីរ គឺ៖ (ក) ការខ្វះចន្លោះផ្នែកចំណេះដឹងសំខាន់ៗ និង (ខ) អាទិភាពសម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវទៅអនាគត ។ នៅខាងដើមវគ្គការពិភាក្សាពេញអង្គ អ្នកតំណាង

ម្នាក់មកពីក្រុមពិភាក្សានីមួយៗ ឡើងបង្ហាញពីលទ្ធផលនៃការពិភាក្សាលើប្រធានបទទាំងពីរក្នុងក្រុមខ្លួន ។ បន្ទាប់មក អ្នកចូលរួមទាំងអស់ បានលើកជាមតិយោបល់បន្ថែម សំណូមពរ និងសំណួរផ្សេងៗ ។

ឯកសារនេះធ្វើសំយោគលទ្ធផលនៃការសិក្សាបូកសរុប និងផ្តល់មតិពីអាទិភាពផ្សេងៗសម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវគោលនយោបាយទៅអនាគត ។ ការធ្វើសំយោគនេះ ផ្អែកលើឯកសារលទ្ធផលស្រាវជ្រាវទាំង៦ បទបង្ហាញចំនួន៧ ក្នុងវគ្គពេលព្រឹក និងបទបង្ហាញក្នុងការពិភាក្សាតាមក្រុមទាំង៣ ក្នុងវគ្គពេលរសៀល ។ ឯកសារ និងបទបង្ហាញទាំងនេះ មានចុះ ក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ។ អត្ថបទនេះ បានចងក្រងលទ្ធផលស្រាវជ្រាវ និងមតិយោបល់សំខាន់ៗ ដោយផ្តុំទៅតាមប្រធានបទទាំងបីដូចតទៅនេះ ។

## យុទ្ធសាស្ត្រ និងគោលនយោបាយវិស័យកសិកម្ម

ប្រទេសកម្ពុជាបានឆ្លងកាត់ការប្រែប្រួលសង្គម សេដ្ឋកិច្ច និងនយោបាយគួរឱ្យកត់សម្គាល់ ចាប់តាំងពីឆ្នាំ១៩៩៣ ។ នៅប៉ុន្មានឆ្នាំថ្មីៗរហូតមកដល់ឆ្នាំ២០០៨ កម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សដោយមានកំណើនប្រចាំឆ្នាំនៃ ផសស (GDP) ដល់ ៩,៨% ដែលជាអត្រាមួយខ្ពស់លើសពីអត្រាកំណើននៃប្រទេសជិតខាង និងអត្រាមធ្យមនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក (World Bank 2009) ។ កំណើនឆាប់រហ័សនេះ មានអមដោយលទ្ធផលគួរឱ្យកត់សម្គាល់ក្នុងវិស័យកសិកម្មដែលបានកើនឡើង ៥,៦% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០០០ និង ២០០៨ ដែលជាអត្រាកំណើនខ្ពស់បំផុតនៅក្នុងតំបន់នៅអំឡុងពេលនោះ ។ ទោះជាយ៉ាងណា សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកលើកសិកម្មខ្លាំងនៅឡើយ ដោយវិស័យនេះរួមចំណែក ជិតស្មើនឹង ១/៣ នៃ ផសស និងប្រើប្រាស់ច្រើនជាងពាក់កណ្តាលនៃកម្លាំងពលកម្មសរុប ។

### យុទ្ធសាស្ត្រ និងគោលនយោបាយវិស័យកសិកម្មដែលមានស្រាប់

ដើម្បីបន្តបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ហើយតាមនេះ បង្កលក្ខណៈឱ្យវិស័យកសិកម្មបន្តដើរតួជាកត្តាជម្រុញយ៉ាងសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏សំខាន់មួយចំនួន ត្រូវបានផ្សព្វផ្សាយ និងអនុវត្តដោយរដ្ឋាភិបាល ។ ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍សំខាន់ៗបំផុតរួមមាន យុទ្ធសាស្ត្រចតុកោណ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG) ឆ្នាំ២០០៣ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទីពីរ (SEDP-II) ឆ្នាំ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ២០០៩-២០១៣ ។ ឯកសារយុទ្ធសាស្ត្រថ្មីៗបំផុតសម្រាប់ វិស័យកសិកម្ម រួមមាន កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩ រៀបចំដោយរដ្ឋបាលព្រៃឈើ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផលឆ្នាំ២០១០-២០១៩ រៀបចំដោយរដ្ឋបាលជលផល និងកម្មវិធីសកម្មភាពជាតិដើម្បីទប់ទល់នឹងការថយចុះគុណភាពដីធ្លីឆ្នាំ២០១១-២០២០ រៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ទោះបីជាគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) គឺដើម្បីកាត់បន្ថយភាពក្រីក្រអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់វិស័យកសិកម្មក៏ដោយ ក៏ NSDP បានចែងផងដែរពីតម្រូវការចំបងឲ្យបង្កើតនូវ យុទ្ធសាស្ត្រជាតិសម្រាប់កសិកម្ម និងទឹក (SAW) ។ គោលដៅចំបងនៃ SAW ឆ្នាំ២០០៦-២០១០ ដែលបានហើយស្រេចបាច់នៅឆ្នាំ២០០៧ គឺការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ហើយនិងការលើកកម្ពស់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក ។ ផ្នែកទីបីនៃឯកសារ SAW គឺ កម្មវិធីគាំទ្រកសិកម្ម និងកសិពាណិជ្ជកម្មកម្ពុជា (CAASP) ដោយផ្តោតលើសន្តិសុខស្បៀង និងស្វ័យផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ (MAFF and MOWRAM 2008) ។ SAW បានដាក់ចេញនូវកម្មវិធីចំនួន ៥ គឺការកសាងសមត្ថភាពស្ថាប័នសន្តិសុខស្បៀង កសិកម្ម និងកសិពាណិជ្ជកម្ម ការគ្រប់គ្រងធនធានទឹក និង ការស្រាវជ្រាវនិងការអភិវឌ្ឍកសិកម្ម ។

តាមការណែនាំក្នុងឯកសារ SAW ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និង ក្រសួងធនធានទឹក និងឧតុនិយម (MWRAM) បានរួមគ្នាបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៦-២០១០ ដោយគូសបញ្ជាក់អំពីគោលដៅអាទិភាពប្រាំពីរ ព្រមទាំងលើកឡើងពីឧបសគ្គនានា និងវិធានការត្រូវប្រកាន់យក ដើម្បីសម្រេចបាននូវគោលដៅទាំងនេះដែលរួមមាន ៖ ១) សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម ២) ការលើកកម្ពស់និងការពង្រឹងការស្រាវជ្រាវកសិកម្ម និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ៣) លទ្ធភាពចូលទៅកាន់ទីផ្សារចំពោះផលិតផលកសិកម្ម ៤) ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ននិងច្បាប់ ៥) កំណែទម្រង់ដីធ្លី របបកម្មសិទ្ធិដីធ្លី និងលទ្ធភាពទទួលបានដីធ្លីចំពោះពលរដ្ឋក្រីក្រ ៦) កំណែទម្រង់ជលផល និង ៧) កំណែទម្រង់ព្រៃឈើ ។

### ដំណាំស្រូវ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យផ្សេងៗ

ស្រូវ គឺជាដំណាំចំបងក្នុងកសិកម្មកម្ពុជា ហើយប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវ គឺជាឆ្អឹងខ្នងនៃកសិកម្មទូទាំងប្រទេស ។ ក្នុងលក្ខណៈជាអាហារមូលដ្ឋានក្នុងរបបហូបចុកជាប្រពៃណី ស្រូវអង្ករផ្តល់លើសពីបីភាគបួននៃថាមពលបានពីការបរិភោគអាហារប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាទូទៅ (MAFF and MOWRAM 2008) ។ ស្រូវក៏ជាកត្តាជំរុញចម្បងមួយនៃកំណើនកសិកម្ម ដែលរួមចំណែកជិតពាក់កណ្តាលនៃកំណើនដំណាំសរុបនៅអំឡុងឆ្នាំ១៩៩៤-២០០៦ ។ ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ស្រូវបានកើនខ្ពស់ជាងទំនិញកសិកម្មនាំចេញជាប្រពៃណីរបស់កម្ពុជា ដូចជា កៅស៊ូ និងផលិតផលព្រៃឈើ ហើយបានក្លាយជាទំនិញកសិកម្មនាំចេញដ៏សំខាន់បំផុត ។

ដោយទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់ស្រូវក្នុងកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការយកចិត្តទុកដាក់ពិសេសដល់វិស័យនេះ ដោយមានសេចក្តីថែងពីផលិតកម្មស្រូវនៅក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងនៅក្នុងឯកសារផែនការនៅរាល់ពេលដែលមានការបញ្ជាក់អំពីកសិកម្ម ។ ឧទាហរណ៍ដូចជា NSDP ឆ្នាំ២០០៦-២០១០ បានកំណត់គោលដៅសម្រាប់ផលិតកម្មស្រូវ តាមរយៈការបង្កើនទិន្នផលស្រូវ និងការពង្រីកផ្ទៃដីមានការស្រោចស្រព ។ នៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០០៨ ស្តីពីការអនុវត្ត NSDP ផែនការផលិតស្រូវត្រូវបានកែសម្រួល ហើយដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ស្រូវប្រកបដោយមហិច្ឆតាខ្ពស់នេះ រាជរដ្ឋាបាលបានបង្កើនវិភាជន៍ទឹកប្រាក់សម្រាប់សកម្មភាពទាក់ទងនឹងដំណាំស្រូវ ដូចជា ការគ្រប់គ្រងកសិកម្មនិងដីធ្លី និងអភិវឌ្ឍន៍ជនបទ ។ វិភាជន៍ទឹកប្រាក់នេះ មានទំហំស្មើនឹង ១៤% នៃធនធានថវិកាឆ្នាំ២០០៦-២០១០ ។

បទបញ្ញត្តិដទៃទៀតសម្រាប់ការអភិវឌ្ឍន៍កសិកម្មម សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ រួមមាន៖ គោលនយោបាយជាតិស្តីពីធនធានទឹក ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម ឆ្នាំ២០០៩-២០១៣ សារាចរលេខ ៣ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅព្រះរាជាណាចក្រកម្ពុជា សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយជាតិចំពោះវិស័យជលផល គោលនយោបាយជាតិស្តីពីវិស័យជលផល និងច្បាប់ជលផល (ឆ្នាំ២០០៦) កម្មវិធីជាតិចំពោះសន្តិសុខស្បៀងគ្រួសារ និងការកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៧-២០១១ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា កម្មវិធីសកម្មភាពជាតិស្តីពីការបន្សាំចំពោះបម្រែបម្រួលអាកាសធាតុ (NAPA) ច្បាប់ស្តីពីវិនិយោគ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ (ឆ្នាំ១៩៩៤ និង ២០០៣) អនុក្រឹត្យស្តីពីការដាក់បញ្ចាំង-ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច (២៩ សីហា ២០០៧) និងព្រះរាជក្រឹត្យ នស/រកត/០៦០៩/០០៩ ដើម្បីផ្តល់កត្តាលើកទឹកចិត្តចំពោះការអភិវឌ្ឍកសិកម្មនៅកម្ពុជា (២០០៩) ។

## ការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ និងចន្លោះខ្វះខាតខាងចំណេះដឹង

នៅកម្ពុជា មានវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយមួយចំនួនដែលចូលរួមចំណែកក្នុងការស្រាវជ្រាវទាក់ទងនឹងគោលនយោបាយ ដូចជា វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា (SNEC) វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍កម្ពុជា (CIDS) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (CBNRM LI) និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) ។ លទ្ធភាពក្នុងការទទួលបានឯកសារស្រាវជ្រាវដែលមានក្នុងក្របខ័ណ្ឌសាធារណៈ នៅមានកំហិតជាខ្លាំង ពិសេសចំពោះវិទ្យាស្ថានស្រាវជ្រាវសាធារណៈ និង ក្រុមវិភាគនានា (think tanks) ។ ការពិនិត្យសាឡើងវិញនេះ ផ្តោតជាសំខាន់លើអនុវិស័យស្រោចស្រព អនុវិស័យដំណាំកសិកម្ម អនុវិស័យជលផល និងអនុវិស័យចិញ្ចឹមសត្វ ប៉ុន្តែផ្នែកពាក់ព័ន្ធដទៃទៀត ក៏មានលើកយកមកពិភាក្សាដែរ ។

ការស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធនឹងទឹក បានគ្របដណ្តប់លើបញ្ហាអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ផលចំណូលសេដ្ឋកិច្ច និងការសិក្សាសាកល្បងមួយចំនួនអំពីកម្មវិធីស្រោចស្រព ។ ការសិក្សាទាំងនេះ បានរកឃើញថា ថ្នាក់ដឹកនាំនៅមានសមត្ថភាពទាប និងស្ថាប័នអន់ខ្សោយ គឺជាឧបសគ្គចំបងនៅក្នុងគម្រោងស្រោចស្រពភាគច្រើន ។ គម្រោងស្រោចស្រពជាច្រើន គេរៀបចំមិនបានល្អទេ ដែលធ្វើឱ្យខ្សត់ទឹក ។ ប្រការនេះនាំឱ្យមានអតុល្យភាពក្នុងការបែងចែកទឹក និងទំនាស់ក្នុងចំណោមអ្នកប្រើទឹកនានា ។ ទំនាស់មួយចំនួនត្រូវបានដោះស្រាយនៅក្នុងសហគមន៍ ប៉ុន្តែទំនាស់ដទៃទៀត ត្រូវការអន្តរាគមន៍ពីអាជ្ញាធរខេត្ត និងអាជ្ញាធរជាតិ ។ ការចូលរួមពីសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ក្នុងការទូទាត់ថ្លៃសេវាផ្គត់ផ្គង់ទឹក ការថែទាំនិងការធ្វើជាម្ចាស់ និងការបែងចែកទឹក គេចាត់ទុកថាមានសារៈសំខាន់បំផុតចំពោះការគ្រប់គ្រងការស្រោចស្រពទឹកប្រកបដោយជោគជ័យ ។ នៅកម្ពុជាពុំទាន់មានការស្រាវជ្រាវពីទឹកក្រោមដីទេ ទោះបីជាមានកំណើនការទាញយកទឹកក្រោមដីក្នុងទ្រង់ទ្រាយតូចក្តី ។ ត្រូវមានការស្រាវជ្រាវស្វែងយល់ពីសក្តានុពលនៃទឹកក្រោមដីដើម្បីក្លាយជាប្រភពទឹកសម្រាប់ការស្រោចស្រព និងសមត្ថភាពនៃទឹកក្រោមដីក្នុងការជួយកាត់បន្ថយផលប៉ះពាល់នៃភាពរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ មកលើកសិកម្ម និងសន្តិសុខស្បៀង ។

កន្លងមក មានការស្រាវជ្រាវមួយចំនួនស្តីពី ពាណិជ្ជកម្មកសិកម្មរវាងប្រទេសកម្ពុជា និងអាស៊ាន និងរវាងអាស៊ាន និងចិន ។ ទំនិញកសិកម្មជាច្រើន ដូចជា បសុសត្វ (ជ្រូក គោ ក្របី) និងដំណាំ (កៅស៊ូ ដំឡូងឈើ ពោត សណ្តែកសៀង ស្រូវ) ត្រូវបានជួញដូរ ។ ពាណិជ្ជកម្មឆ្លងដែននេះ អាចជួយធ្វើឱ្យថ្លៃទីផ្សារមានស្ថិរភាព និងពង្រីកទីផ្សារផលិតផលកសិកម្មកម្ពុជា ។ ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាទទួលបានផលប្រយោជន៍តិចតួចណាស់ ហើយមានកម្លាំងប្រកួតប្រជែងតិចជាងប្រទេសអាស៊ានដទៃទៀត ។ ទំនិញស្ទើរតែទាំងអស់ ត្រូវបាននាំចេញជាផលិតផលមិនទាន់កែច្នៃ ហើយជារឿយៗតាមរយៈការធ្វើពាណិជ្ជកម្មក្រៅផ្លូវការ ។ ប្រទេសថៃ និង វៀតណាម មានឧត្តមភាពជាងប្រទេសកម្ពុជា ដោយសារប្រទេសទាំងនោះធ្វើការកែច្នៃទំនិញជាច្រើនដែលនាំចូលមកពីប្រទេសកម្ពុជា ហើយលក់បន្តទៅកាន់ទីផ្សារពិភពលោក ។ ដូចនេះ ការបន្ថែមតម្លៃតាមរយៈថ្លៃ និងការកែច្នៃផលិតផលកសិកម្មផ្សេងៗ តែងបានទៅដល់បណ្តាប្រទេសជិតខាងកម្ពុជា ។

មានការសិក្សាតិចតួចណាស់អំពីសន្តិសុខស្បៀងនៅប្រទេសកម្ពុជា ។ គេឃើញមានពិពិធកម្មកម្រិតទាបក្នុងលំនាំនៃការប្រើប្រាស់ស្បៀង ហើយស្រូវជាប្រភពអាហារចំបងដែលផ្តល់ថាមពលស្មើនឹងពីរភាគបីនៃបរិមាណអាហារបរិភោគគិតជាកាឡូរីសរុប ខណៈដែលការបរិភោគសាច់ត្រី និងសាច់សត្វ មានចំនួនតិចតួច ដោយទាំងពីរមុខនេះផ្តល់បានត្រឹមតែ ៦% នៃបរិមាណថាមពលគិតជាកាឡូរីសរុបប៉ុណ្ណោះ ។ ការស្រាវជ្រាវដោយប្រើផែនទីសន្តិសុខស្បៀងបង្ហាញថា ខេត្តចំនួន ៩ មានអសន្តិសុខស្បៀងធ្ងន់ធ្ងរ ហើយខេត្តចំនួន ៥ ត្រូវបានសង្កេតឃើញថា មានអត្រាមរណភាព អត្រាទម្ងន់ស្រាល អត្រាគ្រិន និងអត្រាភាពស្គមស្គាំង កម្រិតខ្ពស់ (mortality, underweight, stunting, and wasting) ។ ទោះជាយ៉ាងណាក្តី ការសិក្សាទាំងនេះ បានបញ្ចប់ក្នុងឆ្នាំ២០០៧

ហើយក៏ពុំទាន់មានទិន្នន័យស្រាវជ្រាវថ្មីៗនៅឡើយដែរ ។ ប្រការនេះធ្វើឱ្យគេជួបការលំបាកក្នុងការកំណត់គោលដៅកម្មវិធីសុវត្ថិភាពសង្គម ដើម្បី កាត់បន្ថយភាពងាយរងគ្រោះ ។

ការស្រាវជ្រាវពីគោលនយោបាយជាច្រើន បានផ្តោតលើការនេសាទទឹកសាប ដើម្បីឆ្លើយតបចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីកំណែទម្រង់វិស័យជលផល ។ លទ្ធផលសម្រេចបាន និងនិរន្តរភាពនៃការគ្រប់គ្រងរួមគ្នាលើវិស័យជលផលបានជួបឧបសគ្គ ដោយសារភាពត្រួតស៊ីគ្នានៃសិទ្ធិអំណាចគ្រប់គ្រង ការកម្រិតដែនកំណត់ធនធានមិនទាន់ច្បាស់ និងសមត្ថភាពមានកម្រិតរបស់ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការពង្រឹង និងផ្តល់ការគាំទ្រ ។ ទំនាស់លើធនធាន ក៏អាចកើតមានផងដែរ រវាងការនេសាទ និងការធ្វើកសិកម្ម ដោយសារការដណ្តើមប្រើប្រាស់ធនធានទឹកក្នុងគោលដៅផ្សេងគ្នា ។

គោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីអនុវិស័យបសុសត្វ មិនបានផ្តល់ផែនការយុទ្ធសាស្ត្រដើម្បីដឹកនាំការស្រាវជ្រាវ និងការអភិវឌ្ឍឡើយ ។ ទោះបីជាអនុវិស័យនេះ ដើរតួនាទីយ៉ាងសំខាន់ចំពោះសន្តិសុខស្បៀង និងកម្លាំងអូសទាញសម្រាប់ផលិតកម្មកសិកម្មក្តី ក៏មិនមានការស្រាវជ្រាវថ្មីៗពីគោលនយោបាយលើអនុវិស័យនេះទេ ដូច្នេះត្រូវមានការស្រាវជ្រាវជាបន្ទាន់ ដើម្បីកែលម្អការអភិវឌ្ឍអនុវិស័យនេះ ។ ការសិក្សាសេដ្ឋកិច្ច-សង្គមកិច្ចនៃអនុវិស័យបសុសត្វ គប្បីចាត់ទុកជាអាទិភាព ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម គឺជាការស្រាវជ្រាវថ្មីមួយនៅកម្ពុជា ហេតុនេះទើបមានការសិក្សាតែតិចតួចលើបញ្ហានេះ ។ គេរកឃើញថា ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អវិជ្ជមានមកលើជីវភាពរស់នៅ ។ ប្រាក់ចំណូលរបស់គ្រួសារ បានទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយសារការរានព្រៃធ្វើកសិកម្ម ការខូចខាតផលដំណាំដោយរដូវប្រាំងមានរយៈពេលវែង និងភ្លៀងធ្លាក់មិនទៀងទាត់ ហើយនិងការហាមឃាត់មិនឱ្យចូលព្រៃ ។ ប្រជាជនជនបទ និងទីក្រុង មានចំណេះដឹងមួយចំនួនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសុខភាពមនុស្ស និងកសិកម្ម៖ មនុស្សងាយនឹងកើតជម្ងឺ ធាតុអាកាសក្តៅទៅៗ ហើយទឹកជំនន់ និងព្យុះភ្លៀង កើតមានញឹកញាប់ជាងមុនធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ផលិតកម្មកសិកម្ម ។ អាស្រ័យហេតុនេះ CARDI កំពុងជ្រើសរើសពូជស្រូវ (ស្រូវស្រាល) ដែលអាចផ្តល់ផលក្នុងរយៈពេលខ្លី ដើម្បីកាត់បន្ថយតម្រូវការទឹក ។

## សំណួរគួរស្រាវជ្រាវនាពេលអនាគត

*១. ការអភិវឌ្ឍកសិកម្ម*

១.១ តើគេអាចធ្វើការបែងចែកធនធានយ៉ាងដូចម្តេច ដើម្បីលើកកម្ពស់ការអភិវឌ្ឍកសិកម្ម និងកំណើន? តើការស្រាវជ្រាវកសិកម្មដើម្បីជម្រុញកំណើនកសិកម្ម ត្រូវពង្រីកថែមយ៉ាងដូចម្តេច? តើទីភ្នាក់ងារស្រាវជ្រាវ និងអ្នកប្រើប្រាស់បច្ចេកវិទ្យា ត្រូវមានទំនាក់ទំនងយ៉ាងដូចម្តេច ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព? តើវិធីអ្វីដែលល្អបំផុតសម្រាប់ជម្រុញ និងលើកទឹកចិត្តកសិករឱ្យអនុវត្តវិធីផលិតថ្មីៗ ដើម្បីបង្កើនផលិតភាព និងសន្តិសុខស្បៀង?

១.២ តើត្រូវប្រើប្រាស់បច្ចេកវិទ្យា និងធាតុចូលអ្វីដែលសមស្រប សម្រាប់ជួយបង្កើនផលិតភាពចំពោះអ្នកមានដីតូច ដើម្បីអាចផលិតស្បៀងអាហារបានគ្រប់គ្រាន់សម្រាប់គ្រួសារ? តើមានឱកាសការងារអ្វីផ្សេងសម្រាប់បង្កើនមុខប្រាក់ចំណូលនៅជនបទ ក្រៅពីប្រាក់ចំណូលពីកសិកម្ម ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅ? តើគេអាចធ្វើពិពិធកម្មការងារកសិកម្មយ៉ាងណាបាន ក្រៅពីកសិកម្មផ្អែកលើដំណាំស្រូវដែលមានសមត្ថភាពស្រោចស្រពតិចតួចនេះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅជនបទ និងកាត់បន្ថយភាពក្រីក្រ?

១.៣ តើធ្វើយ៉ាងណាអាចលើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សាឃុំ ក្នុងលក្ខណៈជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់ការផ្ទេរបច្ចេកវិទ្យាទៅឱ្យសហគមន៍? តើកម្មវិធីបណ្តុះបណ្តាលអ្វីខ្លះ មានប្រសិទ្ធភាពល្អសម្រាប់

កសាងសមត្ថភាពក្រុមប្រឹក្សាឃុំ ក្នុងមុខងារជួយផ្ទេរបច្ចេកវិទ្យានេះ? តើការចូលរួមរបស់វិស័យឯកជន នៅក្នុងការផ្ទេរបច្ចេកវិទ្យាចំពោះផលិតករ អាចលើកកម្ពស់យ៉ាងដូចម្តេចបាន? តើការកសាងស្ថាប័ន និងការកសាងសមត្ថភាពរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ត្រូវពង្រឹងយ៉ាងដូចម្តេច ដើម្បីជួយកសិករបង្កើន ផលិតភាពបានកាន់តែមានប្រសិទ្ធភាព? តើធ្វើយ៉ាងណាអាចបែងចែកធនធានបានច្រើនថែមទៀត ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម?

១.៤ តើគោលនយោបាយអ្វីខ្លះ មានប្រសិទ្ធភាពល្អក្នុងការកាត់បន្ថយហានិភ័យ និងអសន្តិសុខស្បៀងដល់ក្រុម គ្រួសារគ្មានដីធ្លី? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះចំពោះគ្រួសារនៅតាមខេត្តនានា ដែលប្រឈម មុខជាមួយអសន្តិសុខស្បៀងធ្ងន់ធ្ងរ? តើធ្វើដូចម្តេចអាចលើកកម្ពស់សម្បទានដីសង្គមកិច្ច ឱ្យកាន់តែមាន ប្រសិទ្ធភាព សម្រាប់គ្រួសារគ្មានដី និងគ្រួសារស្ទើរគ្មានដី? តើគ្រួសារគ្មានដីធ្លីត្រូវប្រឈមមុខនឹងហានិភ័យ និងបញ្ហាសន្តិសុខស្បៀងអ្វីខ្លះ?

១.៥ តើការផ្លាស់ប្តូរបច្ចេកវិទ្យាកសិកម្មអ្វីខ្លះដែលអាចកើតមានក្នុងប្រទេសកម្ពុជា? តើវិស័យកសិកម្ម មាន មុខងារអ្វីខ្លះក្នុងកំណើនសេដ្ឋកិច្ច ឱកាសការងារ សន្តិសុខស្បៀងនៅជនបទ និងទីក្រុង និងការកាត់បន្ថយ ភាពក្រីក្រនាពេលអនាគត?

១.៦ តើហានិភ័យលើផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង អាចកាត់បន្ថយយ៉ាងណាបាន នៅក្រោមការគំរាម កំហែងនៃការប្រែប្រួលអាកាសធាតុ? តើការប្រើប្រាស់ទឹកក្រោមដីប្រកបដោយប្រសិទ្ធភាព អាចរៀបចំ និង ជម្រុញយ៉ាងដូចម្តេចបាន ដើម្បីកាត់បន្ថយការគំរាមកំហែងចំពោះដីកសិកម្ម?

*២. ការពិចារណាឡើងវិញពីឧត្តមភាពប្រៀបធៀបនៃវិស័យស្រូវនៅកម្ពុជា*

មាគ៌ាផ្សេងៗសម្រាប់ឲ្យប្រទេសកម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារស្រូវអង្ករ គឺជាធាតុ ផ្សំដ៏ចាំបាច់សម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ផលិតកម្មស្រូវនៅកម្ពុជា ។ គេត្រូវផ្តោតជាសំខាន់ទៅលើជម្រើស រវាង គោលដៅអភិវឌ្ឍន៍ខុសៗគ្នានៃដំណាំស្រូវ ដូចជា រវាងការបង្កើនទិន្នផល និងការអភិវឌ្ឍដំណាំស្រូវមានគុណភាព ខ្ពស់ និងច្រើនប្រភេទជាដើម ។ ការស្រាវជ្រាវទាំងនេះ ក៏ត្រូវពិចារណាអំពីស្ថានភាពក្បេត្រសាស្ត្រក្នុងស្រុក ផល ប៉ះពាល់ជាសក្តានុពលនៃការប្រែប្រួលអាកាសធាតុទៅលើទិន្នផល និងផ្ទៃដីដំណាំស្រូវនៅក្នុងតំបន់អេកូកសិកម្ម ខុសៗគ្នា ដែលជួយឲ្យគេអាចកំណត់ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជា នៅក្នុងផលិតកម្ម និងការនាំចេញស្រូវ អង្ករ ។ សំណួរដូចខាងក្រោមនេះ អាចជាផ្នែកមួយនៃការស្រាវជ្រាវនាពេលអនាគត៖

២.១ តើមធ្យោបាយអ្វីមានប្រសិទ្ធភាពបំផុត ដើម្បីបង្កើនផលចំណេញនៃដំណាំដល់កសិករ? តើផលិតកម្មមាន ទិន្នផលខ្ពស់ដែលត្រូវការធាតុចូលច្រើន វាមានផលចំណេញសម្រាប់កសិករខ្នាតតូចភាគច្រើន ឬយ៉ាង ណា? តើមានការដោះដូរគ្នាឬទេ រវាងគោលដៅអភិវឌ្ឍន៍ផ្សេងៗនៃដំណាំស្រូវ ហើយនិងចំណាយនិង ផលចំណូលនៃវិនិយោគសាធារណៈដើម្បីសម្រេចគោលដៅទាំងនេះ? តើការដោះដូរនោះ មានអ្វីខ្លះ?

២.២ តើអ្វីខ្លះជាឧត្តមភាពប្រៀបធៀបជាក់ស្តែងនៃវិស័យស្រូវនៅកម្ពុជា? តើមានជម្រើសជាយុទ្ធសាស្ត្រខុសៗ គ្នាច្រើនឬទេ សម្រាប់ការលើកកម្ពស់វិស័យស្រូវ ដូចជា ការលើកកម្ពស់ពូជស្រូវដោយផ្តោតទៅលើរសជាតិ និងគុណភាព ដែលអាចទទួលបានថ្លៃខ្ពស់ ឬក៏ការលើកកម្ពស់ផលិតកម្មទ្រង់ទ្រាយធំមានទិន្នផលខ្ពស់ ប៉ុន្តែមានថ្លៃទាប ជាដើម? តើមានទីផ្សារពិសេសៗសម្រាប់ផលិតកម្មស្រូវកម្ពុជា (ឧ. ផលិតកម្មសរីរាង្គ) ដែរឬទេ?

២.៣ តើអ្វីជាឱកាសទីផ្សារពិតប្រាកដសម្រាប់ការនាំចេញអង្ករកម្ពុជា ក្នុងពេល ៥ ទៅ ១០ឆ្នាំខាងមុខ? ដើម្បី ស្វែងយល់ពីសំណួរនេះ យើងត្រូវកំណត់ពីទីផ្សារសម្រាប់ការនាំចេញស្រូវអង្ករនាពេលបច្ចុប្បន្ន និងទៅ

អនាគត ដោយគិតទាំងការលើកកម្ពស់គោលដៅនាំចេញជាប្រពៃណីគឺមានទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក និងការស្វែងរកបន្ថែមនូវទីផ្សារពិសេសថ្មីៗនៅតាមប្រទេសដែលមានសេដ្ឋកិច្ចកំពុងងើបឡើង ។ ត្រូវមានការសិក្សាស៊ីជម្រៅ ដើម្បីបែងចែកទីផ្សារតាមគុណភាព រសជាតិ និងចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ ។ ទីផ្សារមានសក្តានុពលធំ រួមមាន ទីផ្សារពិសេសនៃអង្ករសរីរាង្គ និងអង្ករពិសេសៗ ។ ឧបសគ្គចំពោះការជ្រៀតចូល និងការពង្រីកទីផ្សារ រួមមាន កង្វះប្រព័ន្ធបែងចែកតាមគុណភាពសម្រាប់ឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិ កង្វះព័ត៌មានទីផ្សារ និងសមត្ថភាពដឹកជញ្ជូននៅមានកម្រិត ដែលត្រូវតែដោះស្រាយ ។ លើសពីនេះទៀត ត្រូវមានគោលនយោបាយដើម្បីលើកកម្ពស់ប្រាក់ចំណូលនៅជនបទ និងជម្រុញការនាំចេញ ។ ក្នុងពេលជាមួយគ្នា ក៏ត្រូវមានការសិក្សាលម្អិតអំពីការដោះដូររវាងការនាំចេញស្រូវអង្ករ និងការផ្គត់ផ្គង់ស្បៀងក្នុងប្រទេស ដើម្បីរក្សាតុល្យភាពល្អរវាងតម្រូវការសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ ។

២.៤ ការស្រាវជ្រាវលម្អិតសព្វគ្រប់ក៏ត្រូវយកចិត្តទុកដាក់ពិនិត្យថា តើកម្ពុជាអាចទាញយកផលចំណេញយ៉ាងណាបានពីស្រូវអង្ករនាំចេញដែលមានតម្លៃបន្ថែមកម្រិតខ្ពស់ ។ ក្នុងនេះ ចាំបាច់ត្រូវមានវិធីសាស្ត្រខ្សែរយៈកំណត់តម្លៃមួយ ។ ការលើកកម្ពស់គុណភាពស្រូវអង្ករក្នុងស្រុក អាចជួយកាត់បន្ថយតម្រូវការនាំចូលស្រូវអង្ករគុណភាពខ្ពស់ និងជួយបង្កើនថ្លៃលក់បាននៅទីផ្សារអន្តរជាតិ ។ ការវិភាគខ្សែរយៈកំណត់តម្លៃពីមុន បានបង្ហាញនូវឧបសគ្គជាច្រើនចំពោះការរក្សាតម្លៃនៅក្នុងប្រទេស ដូចជា ការបាត់បង់ក្រោយពេលប្រមូលផល កន្លែងកែច្នៃមានតិច និងចាស់ហួសសម័យ ចំណាយដឹកជញ្ជូនខ្ពស់ កន្លែងស្តុកមានតិច ឬគ្មាននៅកម្រិតសហគមន៍ ។ វិធីសាស្ត្រខ្សែរយៈកំណត់តម្លៃថ្មី ត្រូវតភ្ជាប់វិស័យស្រូវអង្ករជាមួយនឹងគោលដៅអភិវឌ្ឍន៍ធំទូលាយ ដូចជា ឱកាសការងារនៅជនបទ កំណើនប្រាក់ចំណូល សន្តិសុខស្បៀង ការកែលម្អស្ថានភាពអាហារូបត្ថម្ភ និងការកាត់បន្ថយភាពក្រីក្រ ។

២.៥ តើយុទ្ធសាស្ត្រខុសៗគ្នានៃដំណាំស្រូវ មានផលប៉ះពាល់អ្វីខ្លះទៅលើភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ? គេត្រូវធ្វើការស្រាវជ្រាវច្រើនថែមទៀត ដើម្បីសិក្សាពីឥទ្ធិពលនៃគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រដល់វិស័យកសិកម្ម និងដំណាំជាក់លាក់មួយចំនួន ។ ដើម្បីលើកកម្ពស់ផលិតភាពស្រូវ គួរសិក្សាពីបទពិសោធន៍របស់ប្រទេសថៃ ក្នុងការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍកសិកម្ម ដើម្បីកែលម្អពូជស្រូវឲ្យមានរសជាតិ និងគុណភាពល្អ ។ ត្រូវមានការស្រាវជ្រាវផងដែរ ដើម្បីវាយតម្លៃអំពីចំណាយ និងផលចំណេញនៃវិនិយោគសាធារណៈ នៅក្នុងគោលដៅខុសៗគ្នានៃការអភិវឌ្ឍដំណាំស្រូវ ។ ឧទាហរណ៍ តើការកសាង និងថែទាំប្រព័ន្ធធារាសាស្ត្រ មានឥទ្ធិពលអ្វីខ្លះចំពោះការបង្កើនទិន្នផលដំណាំ និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ? ការស្រាវជ្រាវអំពីមាគ៌ាផ្សេងៗសម្រាប់ការអភិវឌ្ឍស្រូវនៅកម្ពុជា ក៏ត្រូវពិចារណាពីផលប៉ះពាល់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ខុសៗគ្នាសម្រាប់ដំណាំស្រូវ ទៅលើភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅកម្រិតគ្រួសារ តំបន់ និងកម្រិតជាតិ ។

២.៦ ពិពិធកម្មដំណាំ ក៏ជាប្រធានបទស្រាវជ្រាវមួយដ៏សំខាន់ដែរ ។ គួរយកចិត្តទុកដាក់ច្រើនថែមទៀតទៅលើបទពិសោធន៍ និងមេរៀនពីប្រទេសអាស៊ីអាគ្នេយ៍ឯទៀតៗ ដូចជា ដំណាំតំបន់ដីខ្ពស់នៅប្រទេសថៃ និងដំណាំលក់យកប្រាក់នៅប្រទេសវៀតណាម ។ ការស្រាវជ្រាវទាំងនេះ គួរផ្តោតទាំងទៅលើផលិតកម្ម និងពិពិធកម្មការប្រើប្រាស់ ព្រោះបទពិសោធន៍នៃប្រទេសអាស៊ីអាគ្នេយ៍ទៀតៗបង្ហាញថា ផលិតកម្មស្បៀងចម្រុះ អាចនាំឱ្យមានពិពិធកម្មការប្រើប្រាស់ ដែលជួយលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារនៅជនបទ ។ ទំនាក់ទំនងរវាងពិពិធកម្មផលិតកម្ម ពិពិធកម្មការប្រើប្រាស់ និងការកែលម្អអាហារូបត្ថម្ភ ក៏ត្រូវមានការសិក្សាលម្អិតនាពេលអនាគត ។ ប៉ុន្តែការវិភាគទៅលើផ្លែឈើ បន្លែ ពោត ដំឡូង និងដំណាំមាន

តម្លៃផ្សេងៗ នៅមានតិចតួចនៅឡើយ ។ ការបាត់បង់ក្រោយការប្រមូលផលដំណាំ ក៏ជាបញ្ហាធំមួយដែរនៅកម្ពុជា ។

*៣. ការអភិវឌ្ឍអនុវិស័យជលផល*

៣.១ តើការផ្លាស់ប្តូរជលធារសាស្ត្រ មានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះទៅលើ អេកូឡូស៊ីជលផល ជម្រក និងផលិតភាពក្នុងវិស័យនេសាទទឹកសាបនៅកម្ពុជា? តើការផ្លាស់ប្តូរនៃការគ្រប់គ្រងទឹកជំនន់ និងជលធារសាស្ត្រទឹកទន្លេ អាចគ្រប់គ្រងយ៉ាងណាបាន ដើម្បីឱ្យអេកូឡូស៊ីត្រី ជម្រកត្រី និងផលិតភាពត្រីមាននិរន្តរភាព?

៣.២ តើវិធានការអ្វីខ្លះចាំបាច់បំផុត ដើម្បីលើកកម្ពស់អត្ថប្រយោជន៍នៃការអភិវឌ្ឍសហគមន៍ជលផល ដែលមានជាអាទិ៍ ការបង្កើតប្រាក់ចំណូល សន្តិសុខស្បៀង សមធម៌ និងការកាត់បន្ថយភាពក្រីក្រ?

៣.៣ តើមុខងាររបស់ស្ថាប័នពាក់ព័ន្ធនានា (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមហាផ្ទៃ) អាចធ្វើការសហការណ៍ និងសម្របសម្រួលយ៉ាងដូចម្តេចបាន ដើម្បីឱ្យការគ្រប់គ្រងវិស័យជលផលកាន់តែមានប្រសិទ្ធភាព?

៣.៤ តើផលិតកម្មវារីវប្បកម្ម អាចកែលម្អយ៉ាងដូចម្តេចបាន ដើម្បីកាត់បន្ថយការគំរាមកំហែងទៅលើការនេសាទទឹកសាបធម្មជាតិ? តើវារីវប្បកម្មនៅតាមតំបន់ជនបទដែលនៅឆ្ងាយពីកន្លែងនេសាទទឹកសាបអាចជម្រុញយ៉ាងណាបាន ដើម្បីបង្កើនការបរិភោគប្រូតេអ៊ីនសត្វ និងការបង្កើនប្រាក់ចំណូល?

*៤. ការអភិវឌ្ឍអនុវិស័យបសុសត្វ*

៤.១ តើអនុវិស័យបសុសត្វអាចជម្រុញយ៉ាងណាបាន ដើម្បីបង្កើនប្រាក់ចំណូលនៅជនបទ និងសន្តិសុខស្បៀង? តើផលិតកម្មបសុសត្វ និងផលិតកម្មដំណាំ អាចធ្វើសមាហរណកម្មចូលគ្នាយ៉ាងណាបាននៅកម្រិតគ្រួសារ? តើផលិតកម្មបសុសត្វ ផលិតកម្មកសិកម្ម ប្រាក់ចំណូលគ្រួសារនៅជនបទ និងសន្តិសុខស្បៀង មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច? តើផលិតករបសុសត្វខ្នាតតូច ផ្តល់ផលចំណេញសេដ្ឋកិច្ចអ្វីខ្លះ? តើការចិញ្ចឹមសត្វនៅតាមសហគមន៍នៅជនបទ ត្រូវជួបហានិភ័យ និងឧបសគ្គចំបងៗអ្វីខ្លះ? តើហានិភ័យ និងឧបសគ្គទាំងនេះ អាចកាត់បន្ថយយ៉ាងណាបាន?

៤.២ តើទីផ្សារបសុសត្វសម្រាប់ផលិតករខ្នាតតូច អាចអភិវឌ្ឍយ៉ាងណាបាន? តើពាណិជ្ជកម្មឆ្លងកាត់ (ដូចជា គោ ក្របី) អាចជម្រុញយ៉ាងណាបាន ដើម្បីពង្រីកទីផ្សារបសុសត្វ? តើត្រូវមានបទបញ្ញត្តិអ្វីខ្លះ ដើម្បីកែលម្អទីផ្សារបសុសត្វ?

៤.៣ តើផលិតកម្មជ្រូកនៅមូលដ្ឋានអាចកែលម្អយ៉ាងណាបាន ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក? តើមានរបៀបរបបអនុវត្តសមស្របអ្វីខ្លះ សម្រាប់ផលិតកម្មជ្រូក? តើអ្នកចិញ្ចឹមជ្រូកត្រូវជួបហានិភ័យ និងឧបសគ្គអ្វីខ្លះ? តើត្រូវមានបទបញ្ញត្តិ និងគោលនយោបាយអ្វីខ្លះ ដើម្បីកាត់បន្ថយការនាំចូលជ្រូក និងជម្រុញផលិតករក្នុងស្រុក?

*៥. ការគ្រប់គ្រងធនធានទឹក*

៥.១ តើទឹកក្រោមដីមានសក្តានុពលអ្វីខ្លះសម្រាប់ការស្រោចស្រព? តើមានចំណុចខ្លាំង និងចំណុចខ្សោយផ្នែកសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ីអ្វីខ្លះ ក្នុងការប្រើប្រាស់ទឹកក្រោមដីសម្រាប់ការអភិវឌ្ឍកសិកម្ម? តើទឹកក្រោមដីផ្តល់តុល្យភាពសេដ្ឋកិច្ចអ្វីបានខ្លះ រវាងផលប្រយោជន៍ចំពោះ និងផលប៉ះពាល់ទៅលើលក្ខណៈដី និងជីជាតិដី ក្នុងរយៈពេលវែង?

៥.២ តើធ្វើដូចម្តេច ដើម្បីកែលម្អប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកលើផ្ទៃដីនៅតាមប្រព័ន្ធស្រោចស្រពដែលមានស្រាប់? តើធ្វើដូចម្តេច ដើម្បីពង្រឹងការចូលរួមរបស់អ្នកប្រើប្រាស់ទឹកលើផ្ទៃដី ឱ្យមានភាពជាម្ចាស់ និងការថែទាំប្រព័ន្ធស្រោចស្រពប្រកបដោយប្រសិទ្ធភាព? តើវិនិយោគលើការថែទាំប្រព័ន្ធស្រោចស្រព ផ្តល់ផលកម្រៃសេដ្ឋកិច្ចអ្វីខ្លះ?

៥.៣ តើមានទំនាស់អ្វីខ្លះជុំវិញភាពខ្សត់ទឹក និងការបែងចែកធនធានទឹក ហើយតើគេអាចដោះស្រាយបញ្ហាទាំងនេះប្រកបដោយប្រសិទ្ធភាពយ៉ាងណាបាន? តើធ្វើយ៉ាងណាអាចបង្កើនចំណែក និងប្រសិទ្ធភាពនៃវិនិយោគសាធារណៈសម្រាប់ការស្តារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព?

## សន្តិសុខស្បៀង អាហារូបត្ថម្ភ និង ការគាំពារសង្គម

ការពិនិត្យរកមើលយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព និងគោលនយោបាយ ដើម្បីសម្រេចបាននូវសន្តិសុខស្បៀង ត្រូវប្រើវិធីសាស្ត្រចម្រុះ និងគ្រប់ជ្រុងជ្រោយមួយ ដែលចាត់ទុកបញ្ហាអសន្តិសុខស្បៀងនេះថា ជាប់ទាក់ទិននឹងច្រើនវិស័យ និងមានច្រើនកម្រិត ។ នៅក្នុងវិធីសាស្ត្រនេះ សន្តិសុខស្បៀងត្រូវបានកំណត់ទាំងនៅកម្រិតជាតិ និងកម្រិតក្រោមជាតិ (ឧ. កម្រិតម៉ាក្រូ) ហើយនិងនៅកម្រិតគ្រួសារ និងកម្រិតបុគ្គល (កម្រិតមីក្រូ) ។ សន្តិសុខស្បៀងកម្រិតម៉ាក្រូ សំដៅលើតុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការស្បៀងអាហារចំពោះប្រទេសណាមួយ ឬតំបន់ណាមួយ ក្នុងនោះតម្រូវការស្បៀងទាំងផ្នែកបរិមាណ និងគុណភាព អាចដោះស្រាយបានតាមរយៈផលិតកម្មក្នុងស្រុក/នៅមូលដ្ឋាន ឬតាមរយៈការនាំចូល (ផលិតផលអាចរកបាន និងមានថ្លៃសមរម្យ) ។ សន្តិសុខស្បៀងកម្រិតមីក្រូ កំណត់ដោយលទ្ធភាពរបស់គ្រួសារ និងសមាជិកគ្រួសារ ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ និងមានសារធាតុចិញ្ចឹម រួមទាំងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងអាហារូបត្ថម្ភ និងសុខភាព ដូចជា ជម្រកសមស្រប ទឹកស្អាត អនាម័យ និងការថែទាំសុខភាពមូលដ្ឋាន ។

សក្ខីភាពប្រវត្តិសាស្ត្របង្ហាញថា ជាទូទៅ កំណើនសេដ្ឋកិច្ចនាំឱ្យមានការកែលម្អអាហារូបត្ថម្ភរបស់មនុស្ស ។ ទោះជាយ៉ាងណាក្តី ឥទ្ធិពលជ្រាបទៅថ្នាក់ក្រោម អាចត្រូវកាត់ផ្តាច់នៅកម្រិតខុសៗគ្នា និងនៅត្រង់ចំណុចផ្សេងៗគ្នា ។ ភាពខុសគ្នាយ៉ាងធំក្នុងស្ថានភាពអាហារូបត្ថម្ភ និងការកែលម្អពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍដែលមានកម្រិតប្រាក់ចំណូលមធ្យមក្នុងមនុស្សម្នាក់ប្រហាក់ប្រហែលគ្នា បង្ហាញថា កំណើនរបស់ប្រទេសមួយចំនួន ជ្រាបចុះមកក្រោមបានច្រើនជាងប្រទេសមួយចំនួនទៀត ហើយរដ្ឋាភិបាលមួយចំនួនទទួលបានជោគជ័យច្រើនក្នុងការប្រើកំណើនសេដ្ឋកិច្ច ដើម្បីកែលម្អស្ថានភាពអាហារូបត្ថម្ភកាន់តែល្អប្រសើរ រដ្ឋាភិបាលមួយចំនួនទៀតទទួលជោគជ័យតិច ហើយមានរដ្ឋាភិបាលខ្លះត្រូវទទួលបរាជ័យ ។ អ្នកទទួលជោគជ័យ គឺជាប្រទេសដែលបានរៀបចំកញ្ចប់គោលនយោបាយមានប្រសិទ្ធភាពល្អ ក្នុងការជម្រុញកំណើនប្រាក់ចំណូលមានមូលដ្ឋានធំទូលាយ និងមានស្ថិរភាព ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្រីក្រ និងដែលមានគួបផ្សំដោយអន្តរាគមន៍ផ្សេងៗផ្តោតចំក្រុមប្រជាពលរដ្ឋងាយរងគ្រោះបំផុត ។ ទោះបីជម្រើសគោលនយោបាយតែងមានលក្ខណៈដោយឡែកតាមប្រទេសក្តី ប៉ុន្តែបណ្តាប្រទេសទទួលជោគជ័យដែលមានស្ថានភាពពីដំបូងប្រហាក់ប្រហែលគ្នា ច្រើនតែមាននិន្នាការដូចគ្នា ហើយដើរតាមគន្លងប្រហាក់ប្រហែលគ្នា ។

## ផលសម្រេចថ្មីៗក្នុងការកែលម្អអាហារូបត្ថម្ភ និងសន្តិសុខស្បៀង

ក្នុងប៉ុន្មានឆ្នាំថ្មីៗ ជាមួយនឹងកំណើនសេដ្ឋកិច្ចឆាប់រហ័ស កម្ពុជាបានទទួលជោគជ័យក្នុងការកែលម្អសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។ ល្បឿននៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា អាចប្រដូចទៅនឹងល្បឿននៅប្រទេសជោគជ័យដទៃទៀតនៅតំបន់អាស៊ី (ដូចជា ចិន និង វៀតណាម) ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍរបស់ពួកគេ ។ ប្រេវ៉ាឡង់នៃអាហារូបត្ថម្ភមិនគ្រប់គ្រាន់ដែលជាសូចនាករសម្រាប់វាស់វែងស្ថានភាពអត់ឃ្លាន

នៅកម្រិតជាតិ បានធ្លាក់ចុះពី ៣៨% នៅឆ្នាំ១៩៩២ មកត្រឹម ២៥% នៅឆ្នាំ២០០៦ ដែលប្រហាក់ប្រហែលគ្នានឹងការធ្លាក់ចុះនៃអត្រាភាពក្រីក្រដែរ ។ ប៉ុន្តែការប្រៀបធៀបរវាងប្រទេសបង្ហាញថា ប្រេវ៉ាឡង់នៃអាហារូបត្ថម្ភមិនគ្រប់គ្រាន់នៅកម្ពុជា មានកម្រិតស្ទើរតែស្មើគ្នានឹងប្រេវ៉ាឡង់នៅប្រទេសបង់ក្លាដេស និងខ្ពស់ជាងនៅ ឥណ្ឌា និងឡាវ បើទោះជា ឡាវមានចំណូលគិតក្នុងមនុស្សម្នាក់ទាបជាងកម្ពុជាក្តី ។

កម្ពុជាក៏សម្រេចជោគជ័យគួរឲ្យកត់សម្គាល់ដែរ ក្នុងការកាត់បន្ថយអត្រាកង្វះអាហារូបត្ថម្ភកុមារក្នុងអំឡុងពីរទសវត្សរ៍កន្លងទៅ ។ នៅឆ្នាំ១៩៩៦ កុមារអាយុក្រោម៥ឆ្នាំ ៥៩% ជាកុមារក្រិន និង ៤៣% មានទម្ងន់ស្រាល ប៉ុន្តែអត្រានេះធ្លាក់មកត្រឹម ៤០% និង ២៩% នៅឆ្នាំ២០០៨ ។ អត្រាស្លាប់របស់កុមារអាយុក្រោម៥ឆ្នាំ នៅកម្ពុជាមានកម្រិតខ្ពស់បើធៀបនឹងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ដទៃទៀត ។ បើទោះជាការកាត់បន្ថយអត្រាស្លាប់របស់កុមារ បានកើនល្បឿនចាប់ពីឆ្នាំ២០០០ មកក្តី ក៏នៅមានកុមារកម្ពុជា ៩០នាក់ ក្នុងចំណោម ១០០០នាក់ ត្រូវស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ សុខភាពទន់ខ្សោយ ឬដោយមូលហេតុអាចទប់ស្កាត់បានផ្សេងៗទៀត នៅឆ្នាំ២០០៨ ធៀបនឹងអត្រាស្លាប់ ១១៧នាក់ក្នុងចំណោម ១០០០នាក់ កាលពីឆ្នាំ១៩៩០ ។ ពិតណាស់ កម្ពុជាទំនងមិនអាចបំពេញបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ ស្តីពីការកាត់បន្ថយឲ្យបានពីរភាគបីនូវអត្រាស្លាប់របស់កុមារអាយុក្រោម៥ឆ្នាំនៅឆ្នាំ១៩៩០ ឲ្យចុះដល់ ៤០នាក់ ក្នុងចំណោម ១០០០នាក់នៅឆ្នាំ២០១៥ ។

ការប្រៀបធៀបកម្ពុជា ជាមួយនឹងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់អាស៊ីខាងត្បូងមួយចំនួន ដូចជា បង់ក្លាដេស ឥណ្ឌា ឡាវ ថៃ និងវៀតណាម បង្ហាញថា ដំណាក់កាលនៃការអភិវឌ្ឍ និងសន្តិសុខស្បៀងនៅកម្ពុជា មានលក្ខណៈស្រដៀងនឹងការវិវត្តរបស់ប្រទេសឡាវ និងបង់ក្លាដេស នាពេលបច្ចុប្បន្ន ប្រទេសវៀតណាមនៅដើមទសវត្សរ៍២០០០ និងប្រទេសថៃកាលពីទសវត្សរ៍១៩៧០ ។ និន្នាការប្រវត្តិសាស្ត្របង្ហាញថា កម្ពុជាហាក់ដើរតាមគន្លងរបស់ប្រទេសចិន និងវៀតណាម ដែលកំណើនសេដ្ឋកិច្ចខ្ពស់បានជួយកាត់បន្ថយបានយ៉ាងច្រើន នូវភាព ក្រីក្រ ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ផ្ទុយពីករណីប្រទេសឥណ្ឌាដែលនៅទីនោះការអភិវឌ្ឍពុំបានផ្តល់ប្រយោជន៍ដល់ក្រុមប្រជាជនក្រីក្រទេ ។ ប៉ុន្តែការកែលម្អអាហារូបត្ថម្ភ និងសន្តិសុខស្បៀងតាមគ្រួសារ បានថយ ល្បឿនក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ម្យ៉ាងទៀត វិសមភាពប្រាក់ចំណូល បានកើនឡើងស្របគ្នានឹងកំណើនសេដ្ឋកិច្ច ហើយ អត្រាកំណើនប្រជាជននៅមានកម្រិតខ្ពស់នៅឡើយ ។ កត្តាទាំងនេះបានរារាំងដល់ដំណើរការរបស់កម្ពុជា ដើម្បីសម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរឡើង ជាពិសេសនៅពេលដែលសេដ្ឋកិច្ចមានកំណើនយឺតដោយសារវិបត្តិសាកលនាពេលថ្មីៗនេះ ។

តាមសេចក្តីដូចខាងលើ ត្រូវមានគោលនយោបាយ កម្មវិធី វិនិយោគ ដ៏មានប្រសិទ្ធភាព ដើម្បីរុញច្រានប្រទេសកម្ពុជាចូលក្នុង គន្លងកំណើនសេដ្ឋកិច្ចនិងអាហារូបត្ថម្ភប្រកបដោយជោគជ័យវិញ ។ ចិន និង វៀតណាម អាចជាឧទាហរណ៍បង្ហាញពីរបៀបល្អប្រសើរក្នុងការប្រើកំណើនសេដ្ឋកិច្ច ដើម្បីសម្រេចបានសន្តិសុខស្បៀងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងកម្រិតគ្រួសារ ហើយបង់ក្លាដេស អាចជាឧទាហរណ៍នៃអន្តរាគមន៍ប្រកបដោយជោគជ័យក្នុងការកាត់បន្ថយយ៉ាងសក្តិសិទ្ធិនូវអត្រាកង្វះអាហារូបត្ថម្ភ ទោះបីពុំមានកំណើនសេដ្ឋកិច្ចខ្លាំងក្លាក្តី ។

## ចន្លោះខ្វះខាតខាងចំណេះដឹង និងវិស័យសម្រាប់ការស្រាវជ្រាវទៅថ្ងៃមុខ

ចន្លោះខ្វះខាតខាងទិន្នន័យ ព័ត៌មាន និងចំណេះដឹងសំខាន់ៗដែលយើងកំណត់បាន មាន ៥ចំណុច គឺៈ (១) កង្វះប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់វិភាគលើលទ្ធផលការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគាំពារសង្គម អាហារូបត្ថម្ភ និងសន្តិសុខស្បៀងដែលមានស្រាប់ ព្រមទាំងសម្រាប់សម្របសម្រួល និងធ្វើសុខដុមនីយកម្មលើយុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះ នៅថ្នាក់ឃុំ និងថ្នាក់ជាតិ ។ (២) កង្វះព័ត៌មានស្តីពីផលចំណេញបានពីវិនិយោគក្នុងវិធានការគាំពារសង្គម ។ (៣) ការវាយតម្លៃមិនគ្រប់គ្រាន់លើកម្មវិធីគាំពារសង្គមដែលមានស្រាប់ ។ (៤) កង្វះទិន្នន័យ និងភស្តុតាងបញ្ជាក់ពីដែនគ្របដណ្តប់នៃកម្មវិធីគាំពារសង្គម ដោយពិនិត្យ

តាមកម្រិតជំនួយអប្បរមា និងអាទិភាពក្នុងការផ្តោតឲ្យចំតំបន់ភូមិសាស្ត្រ និងវិស័យសេដ្ឋកិច្ចដែលនៅខ្វះខាតធ្ងន់ធ្ងរបំផុត ។ (៥) កង្វះចំណេះដឹងស្តីពីឥទ្ធិពលនៃការផ្លាស់ ប្តូរប្រព័ន្ធផលិតកម្មកសិកម្ម (ប្រពលវប្បកម្ម និងពិពិធកម្មការដាំដុះ ការចិញ្ចឹមសត្វ និង ការនេសាទ) ទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

តាមរយៈការពិភាក្សាតាមក្រុមនៅក្នុងកិច្ចប្រជុំបូកសរុប អាទិភាពសម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវទៅថ្ងៃមុខ ក៏បានកំណត់ឡើង ដើម្បីដោះស្រាយបញ្ហាការខ្វះខាតផ្នែកចំណេះដឹងផ្សេងៗ ។ អាទិភាពទាំងនោះ រួមមាន៖ (១) ការវិភាគពីប្រសិទ្ធភាពនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់ (មានទាំងអត្រាប្រាក់ចំណេញពីវិនិយោគ) សម្រាប់ការតស៊ូមតិដោយមានភស្តុតាងជាសំអាង ដើម្បីធ្វើការវាយតម្លៃលើវិនិយោគពីពេលមុនៗ និងនៅពេលអនាគត ធ្វើការរចនារៀបចំកម្មវិធីឲ្យបានកាន់តែប្រសើរ ព្រមទាំងពង្រីកកម្មវិធីមានស្រាប់នានាដែលទទួលបានជោគជ័យ ។ (២) ការបង្កើតវេទិកាប្រមូលព័ត៌មាន និងទិន្នន័យមួយ សម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីគាំពារសង្គម ព្រមទាំងធ្វើអន្តរាគមន៍ឲ្យកាន់តែចំគោលដៅ ។ (៣) ការវិភាគកត្តាសំខាន់ៗដែលរួមចំណែកក្នុងកង្វះអាហារូបត្ថម្ភ និងអសន្តិសុខស្បៀង និងការយកចិត្តទុកដាក់ជាពិសេសលើលំនាំនៃចំណាយលើម្ហូបអាហារ ក៏ដូចជា ទំលាប់នៃការប្រើប្រាស់ម្ហូបអាហាររបស់ប្រជាជន ។ (៤) ការវិភាគពីឥទ្ធិពលនៃការកែលម្អប្រព័ន្ធផលិតកម្មកសិកម្មទៅលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និង (៥) ការវិភាគពីផលប៉ះពាល់ខាងអាហារូបត្ថម្ភ និងសន្តិសុខស្បៀង នៃគោលនយោបាយអភិវឌ្ឍន៍ជាតិ និងអន្តរាគមន៍ផ្សេងៗ (ឧ. ការសង់ទំនប់ទប់ស្ទឹងទន្លេ) ក៏ដូចជា ការប៉ះទង្គិចពីខាងក្រៅផ្សេងៗទៀត ។

ដោយទទួលស្គាល់ពីលក្ខណៈជាប់ទាក់ទងច្រើនវិស័យនៃបញ្ហាអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ព្រមទាំងសារៈសំខាន់នៃការគាំពារសង្គមក្នុងការលុបបំបាត់បញ្ហាទាំងនេះ អ្នកចូលរួមក្នុងការពិភាក្សាតាមក្រុម ក៏បានលើកឡើងដែរអំពីកត្តាជាច្រើនទៀត ក្រៅពីបញ្ហាខាងគោលនយោបាយ និងអន្តរាគមន៍ដែលផ្តោតចំទៅលើអសន្តិសុខស្បៀង ។ កត្តាទាំងនេះរួមមាន តួនាទីនៃព័ត៌មាននិងការអប់រំ តួនាទីនៃយេនឌ័រ សក្តានុពលនៃការបន្ថែមសារធាតុចិញ្ចឹមក្នុងអាហារ ការផ្តល់អាហារបន្ថែម និងការបង្កាត់ពូជដំណាំដែលមានសារធាតុចិញ្ចឹមខ្ពស់ តម្រូវការទិន្នន័យលម្អិតលើអាហារូបត្ថម្ភបុគ្គល បញ្ហាប្រឈមនៃការអភិវឌ្ឍកសិកម្ម និងវិនិយោគជាប់ទាក់ទិន (ដូចជា ការស្រោចស្រពជាដើម) តួនាទីនៃការកំណត់ថ្លៃអាហារនៅលើទីផ្សារ និងថ្លៃលក់រាយនៅតាមមូលដ្ឋាន ព្រមទាំង អភិបាលកិច្ចល្អ និងឆន្ទៈក្នុងការបញ្ជ្រាបនូវគោលនយោបាយនៅតាមក្រសួង និងស្ថាប័នរដ្ឋនៅតាមកម្រិតខុសៗគ្នា ។

ចំណេះដឹង ព័ត៌មាន និងចន្លោះខ្វះខាតខាងទិន្នន័យ ព្រមទាំងអាទិភាពសម្រាប់ការស្រាវជ្រាវទៅថ្ងៃខាងមុខ ត្រូវផ្អែកលើការប្រមូលទិន្នន័យបឋម និងទិន្នន័យផ្សេងទៀត ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីបច្ចុប្បន្ន ។ ការងារនេះប្រហែលអាចអនុវត្តបានល្អបំផុតដោយស្ថាប័នស្រាវជ្រាវក្នុងស្រុក និងទីភ្នាក់ងាររដ្ឋាភិបាលដោយមានជំនួយគាំទ្រពី IFPRI ។ ទាក់ទិននឹងផ្នែកសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការគាំពារសង្គម គេគួរផ្តោតការយកចិត្តទុកដាក់លើការស្រាវជ្រាវក្នុងរយៈពេលខ្លី និងមធ្យម លើបញ្ហាដូចតទៅ៖ (១) ការវិភាគពីលំនាំចំណាយលើអាហារ ការប្រើប្រាស់ស្បៀងអាហារ និងរបៀបរបបបរិភោគ ព្រមទាំងស្ថានភាពមានកង្វះអាហារូបត្ថម្ភ ភាពអត់ឃ្លាន និងភាពក្រីក្រក្នុងតំបន់ជាក់លាក់ណាមួយ ក្នុងពេលបច្ចុប្បន្ន ក្នុងអតីតកាល និងការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ (២) ការវិភាគពីមូលហេតុបឋមដែលបង្កអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ នៅកម្រិតជាតិ កម្រិតស្រុក កម្រិតគ្រួសារ និងកម្រិតបុគ្គល អន្តរកម្មរវាងកម្រិតទាំងនេះ និងកម្លាំងចម្រុះផ្សេងៗ ដើម្បីកែលម្អស្ថានភាពអាហារូបត្ថម្ភ (ក្នុងនេះ មានទាំងទិដ្ឋភាពផ្សេងៗ ដូចជា ការអប់រំ យេនឌ័រ សុខភាព ការធ្វើចំណាកស្រុក កំណើន និងការប្រែប្រួលខាងសេដ្ឋកិច្ច និងថ្លៃលើទីផ្សារ) (៣) ការវិភាគពីទំនាក់ទំនងរវាងប្រព័ន្ធផលិតកម្មកសិកម្មដែលមានស្រាប់ ជាមួយនឹងសុខភាព និងអាហារូបត្ថម្ភរបស់ប្រជាជន (៤) ការកំណត់លក្ខណៈសម្គាល់នៃប្រជាជនងាយរងគ្រោះ និងការវាយតម្លៃពីកម្មវិធីគាំពារសង្គមដែលមានស្រាប់សម្រាប់ក្រុមជនងាយរងគ្រោះទាំងនោះ (៥)

ការវិភាគពីផលប៉ះពាល់ខាងអាហារូបត្ថម្ភ និងសន្តិសុខស្បៀង នៃគោលនយោបាយវិនិយោគ និង អន្តរាគមន៍ផ្សេងៗទៀត ក៏ដូចជា ការប៉ះទង្គិចពីផ្នែកខាងក្រៅផ្សេងៗ ដូចជា បម្រែបម្រួលអាកាសធាតុ ជាប់ទាក់ទិននឹងព្រឹត្តិការណ៍ និងវិបត្តិសេដ្ឋកិច្ចសាកល ជាដើម និង (៦) ការកំណត់នូវគោលនយោបាយ វិនិយោគ និងកម្មវិធីដ៏មានប្រសិទ្ធភាពនានា ដើម្បីជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចដែលមានគុណភាពល្អ និងការកែលម្អស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ។

បញ្ហាសម្រាប់ការស្រាវជ្រាវ នឹងត្រូវបានដោះស្រាយដោយប្រើវិធីសាស្ត្រជឿនលឿនផ្សេងៗ និងដោយគួបផ្សំ ប្រភពទិន្នន័យដែលមានស្រាប់ ព្រមទាំងភស្តុតាងបានពីការសិក្សាលើឯកសារយោងទាក់ទងនឹងវិជ្ជាជីវៈផ្សេងៗ ។ ប្រភពទិន្នន័យដែលអាចរកបាន រួមមាន អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) អង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា (DHS) ជំរឿនប្រជាជនកម្ពុជា សៀវភៅស្ថិតិប្រចាំឆ្នាំ ស្ថិតិគណនេយ្យជាតិ និងប្រភពដទៃទៀតបានពីទីភ្នាក់ងារជាតិ និងអន្តរជាតិ ។

## ធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ

### ហេតុអ្វីបានជាអភិបាលកិច្ចធនធានធម្មជាតិមានសារៈសំខាន់

ប្រទេសកម្ពុជា មានកំណើនសេដ្ឋកិច្ចឆាប់រហ័សអស់រយៈពេលមួយទសវត្សរ៍រហូតដល់ឆ្នាំ២០០៨ ។ ការសម្លឹងឆ្ពោះទៅអនាគត ក៏មានលក្ខណៈច្បាស់លាស់ផងដែរដែលថា ការធ្វើឱ្យមាននិរន្តរភាពកំណើន និងការពង្រីកផលប្រយោជន៍ឱ្យបានដល់ប្រជាពលរដ្ឋងាយរងគ្រោះនៅតាមផ្នែកផ្សេងៗ តម្រូវឱ្យមានការប្រឈមមុខជាមួយនឹងហានិភ័យធ្ងន់ធ្ងរមួយចំនួន ។ វិសមភាព បានកើនឡើងយ៉ាងឆាប់រហ័ស ហើយកង្វះធនធាន គឺជាប្រភពចំបងនៃភាពងាយរងគ្រោះចំពោះគ្រួសារនៅជនបទ និងក៏ជាមូលហេតុសំខាន់មួយ បណ្តាលឱ្យភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភតែងកើតមានជានិច្ចកាល ។ វិនិយោគលើវិស័យសុខាភិបាល វិស័យអប់រំ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងមីក្រូឥណទាន មានសារៈសំខាន់ក្នុងការជួយបង្កើនទ្រព្យសម្បត្តិ (asset portfolio) របស់គ្រួសារដែលមានភាពងាយរងគ្រោះ ហើយតម្រូវការចាំបាច់ និងបន្ទាន់បំផុតនោះ គឺការធានាឱ្យពួកគេមានលទ្ធភាពទទួលបានផលពីធនធានធម្មជាតិ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតនៅតាមជនបទ ។

ចំពោះប្រជាជននៅជនបទដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម ល្បឿនឆាប់រហ័សនៃការប្រមូលផ្តុំក្នុងការកាន់កាប់ដីធ្លី សភាពកើតមានទូទៅនៃទំនាស់ដីធ្លី និងបរាជ័យដែលមានលក្ខណៈជាប្រព័ន្ធ ក្នុងការដោះស្រាយទំនាស់នានា ពិតជាបង្កឱ្យមានកង្វល់ច្រើន ។ លទ្ធភាពទទួលបានធនធានធម្មជាតិប្រកបដោយសមធម៌ គឺជាកត្តាមួយមានសារៈសំខាន់ជាខ្លាំងនៃសំណាញ់សុវត្ថិភាពសង្គម សម្រាប់គ្រួសារក្រីក្រនៅជនបទ ពិសេសនៅក្នុងប្រទេសមួយ ដូចជាប្រទេសកម្ពុជាជាដើម ដែលកម្មវិធីការពារសង្គមផ្លូវការនៅមានភាពខ្វះចន្លោះជាខ្លាំង ហើយធនធានរបស់រដ្ឋក្នុងការផ្តល់មូលនិធិមកលើចំណុចទាំងអស់នេះ មានកម្រិតតិចតួច ។ នៅក្នុងរយៈពេលវែង សមធម៌ចំពោះការកាន់កាប់ដីធ្លី ត្រូវបានបង្ហាញថា បានរួមចំណែកយ៉ាងច្រើនចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងអន្តរកាលពីសេដ្ឋកិច្ចកសិកម្ម ទៅកាន់សេដ្ឋកិច្ចឧស្សាហកម្មទំនើប ដូចករណីនៅប្រទេសជប៉ុន តៃវ៉ាន់ និងកូរ៉េខាងត្បូងជាដើម ។

ការធ្វើឱ្យមាននិរន្តរភាពចំពោះកំណើន ការកាត់បន្ថយភាពក្រីក្រ និងការពង្រឹងសន្តិសុខស្បៀង ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ចាំបាច់ត្រូវធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទកម្ពុជា និងកែប្រែការចាត់ចែងផ្នែកស្ថាប័ន និងអភិបាលកិច្ច ដោយផ្អែកលើមូលដ្ឋានឧត្តមភាពប្រៀបធៀបរបស់កម្ពុជា ដែលសម្បូរណ៍ដីធ្លី មានសម្បត្តិធម្មជាតិដែលមានគុណភាពខ្ពស់ និងមានពលកម្មក្នុងតម្លៃថោក ។ រហូតមកដល់ពេលនេះ ការរួមចំណែកភាគច្រើននៃវិស័យធនធានធម្មជាតិចំពោះកំណើន គឺដោយសារការធ្វើអាជីវកម្មផ្អែកលើមូលដ្ឋានទ្រព្យសម្បត្តិ ជាជាងការ

គ្រប់គ្រងដោយនិរន្តរភាព ។ សារៈសំខាន់ជាចំបងនៃអភិបាលកិច្ចធនធានធម្មជាតិ គឺការរួមចំណែកចំពោះសន្តិសុខស្បៀង និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។

**យុទ្ធសាស្ត្រចំពោះអភិបាលកិច្ចធនធានធម្មជាតិ**

គេឃើញមានការរីកចម្រើនគួរឱ្យកត់សម្គាល់ អំពីគោលនយោបាយស្តីពីធនធានធម្មជាតិនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជាអាទិ៍ ការព្យួរ ឬការដកយកសម្បទានព្រៃពាណិជ្ជកម្មស្ទើរតែទាំងអស់ និងការអនុម័តបទបញ្ញត្តិ ដើម្បីគាំទ្រសហគមន៍ជលផល និងសហគមន៍ព្រៃឈើ ក៏ដូចជាគំនិតផ្តួចផ្តើមមួយចំនួន ក្នុងការបង្កើនការផ្តល់កម្មសិទ្ធិដីធ្លីនៅជនបទ និងកសាងសមត្ថភាពដើម្បីដោះស្រាយវិវាទដីធ្លី ។ ប៉ុន្តែកន្លងមក អត្ថប្រយោជន៍នៃវិធានការទាំងនេះមានតិចតួច ធៀបនឹងហានិភ័យថ្មីៗ ដែលសហគមន៍ជនបទប្រឈមមុខ ។

បញ្ហាទំនាស់អំពីសិទ្ធិដីធ្លី រួមមានទាំងលើដីកសិកម្ម និងដីព្រៃ តួយ៉ាងដូចជាកសិករក្រីក្របំផុត និងសហគមន៍ពឹងផ្អែកលើព្រៃឈើ មានទំនាស់ជាមួយផ្នែកឯកជនដែលមានទំនាក់ទំនងផ្នែកនយោបាយ យោធា និង/ឬស្ថាប័ននានារបស់រដ្ឋ ។ ចំណុចត្រួតគ្នាលើតំបន់ដែលបានកំណត់សម្រាប់សម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ តំបន់ព្រៃឈើគ្រប់គ្រងដោយសហគមន៍ និងដីកសិកម្មតូចៗ កំពុងជម្រុញឱ្យមានការតតាំង បាតុកម្ម និងទំនាស់នៅមូលដ្ឋានសាជាថ្មី ។ ក្រុមរៀបចំសហគមន៍ និងក្រុមសង្គមស៊ីវិលដែលបានការពារសិទ្ធិប្រើប្រាស់ធនធានសម្រាប់ប្រជាជនមូលដ្ឋាន បានបរាជ័យជាហូរហែរក្នុងការសម្រេចបាននូវដំណោះស្រាយតាមរយៈតុលាការ ហើយពណ៌នាអំពីបរិយាកាសនិទណ្ឌភាព និងភាពលំអៀងដែលមានលក្ខណៈជាប្រព័ន្ធ ចំពោះអ្នកប្រើប្រាស់ធនធាន ក្រុមជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដទៃទៀត ។

ដូចគ្នាដែរ នៅក្នុងវិស័យជលផល ទោះបីជាមានការផ្លាស់ប្តូរគោលនយោបាយយ៉ាងច្រើន ដែលកាត់បន្ថយផ្ទៃដីសម្បទានពាណិជ្ជកម្ម ក្នុងការផ្តល់លទ្ធភាពប្រើប្រាស់ដល់សហគមន៍នៅឆ្នាំ២០០០/២០០១ ទំនាស់រវាងអ្នកនេសាទបែបពាណិជ្ជកម្ម និងអ្នកនេសាទចិញ្ចឹមក្រពះ នៅតែកើតមានទន្ទឹមគ្នានឹងបញ្ហាប្រឈមមុខថ្មីៗ រួមមានការប្រជែងប្រើប្រាស់ទឹក និងដី នៅក្នុងតំបន់វាលទំនាប និងផលប៉ះពាល់ដែលអាចកើតមាននៃហេដ្ឋារចនាសម្ព័ន្ធថ្មីជាពិសេសទំនប់ទឹក ។ គ្មានក្របខ័ណ្ឌដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបានបង្កើតឡើងដើម្បីប៉ាន់ស្មានអំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងផលប៉ះពាល់ផ្នែកសង្គមនៃគម្រោងថ្មីៗឡើយ រាប់ទាំងគម្រោងថាមពលវារីអគ្គិសនី ប្រព័ន្ធស្រោចស្រព និងប្រតិបត្តិការរ៉ែ ហើយក៏គ្មានការថ្លឹងថ្លែងចំណុចទាំងអស់នេះ ជាមួយនឹងផលប្រយោជន៍រំពឹងទុកប្រកបដោយលក្ខណៈសត្យានុម័តនោះទេ ។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកអភិបាលកិច្ចល្អជាស្នូល ហើយគូសបញ្ជាក់វិស័យកសិកម្ម (រាប់ទាំងព្រៃឈើ និងជលផល) ថាជា "ចតុកោណកំណើនយុទ្ធសាស្ត្រ" ទីមួយ ក្នុងចំណោមចតុកោណកំណើនយុទ្ធសាស្ត្របួនដែលតម្រូវឱ្យមានការគាំទ្រជាអាទិភាព ។ ប៉ុន្តែ ទោះជាមានទិសដៅគោលនយោបាយរួមបែបនេះក្តី ការប្រកួតប្រជែង និងទំនាស់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិបច្ចុប្បន្ន និងផែនការប្រើប្រាស់ធនធានធម្មជាតិ បង្ហាញតម្រូវការឱ្យមានឋានានុក្រមច្បាស់លាស់ នូវគោលដៅអភិបាលកិច្ចធនធានធម្មជាតិ ក្នុងទំនាក់ទំនងជាមួយកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង ពិពិធកម្មចំពោះការចិញ្ចឹមជីវិត សមធម៌ ស្ថិរភាពសង្គម និងសុខុមាលភាពសហគមន៍ ។ ការពិភាក្សាអំពីគោលនយោបាយនៅក្នុងក្របខ័ណ្ឌនេះ អាចគាំទ្រដោយការស្រាវជ្រាវផ្អែកលើភស្តុតាង ដែលមានគោលដៅគូសបញ្ជាក់ទិដ្ឋភាពអភិវឌ្ឍន៍តាមបែបផ្សេង និងផលប៉ះពាល់នៃការអភិវឌ្ឍទាំងនោះទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ឬគោលដៅនានា ដូចចំណុចដែលបានលើកឡើងខាងលើដោយទាញចេញនូវការវិភាគអំពីនិន្នាការអភិវឌ្ឍន៍ និងបទពិសោធន៍នៅកម្ពុជា ក៏ដូចជានៅប្រទេសកំពុងអភិវឌ្ឍដទៃទៀត និងក្នុងតំបន់នានា ។

## ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើប្រទេសកម្ពុជា ពុំមែនមានប្រភពមកតែពីការប្រែប្រួលផលិតកម្មនៅក្នុងស្រុកឡើយ ។ កម្ពុជាគឺជាប្រទេសនាំចេញស្រូវអង្ករ ដូច្នេះ កំណើនថ្លៃពិភពលោក អាចបង្កើនតម្លៃសរុបនៃបរិមាណស្រូវ/អង្ករផលិតក្នុងស្រុក ។ ម្យ៉ាងវិញទៀត កសិករជាច្រើនមិនបានផលិតស្រូវគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឡើយ ហើយពួកគេត្រូវទិញស្បៀងអាហារតាមរដូវកាល ។ ចំពោះគ្រួសារខ្សត់ដីវិបត្តិផលិតភាពអវិជ្ជមាន អាចកាត់បន្ថយប្រាក់ចំណូលកសិកម្ម និងធ្វើឱ្យថ្លៃស្បៀងអាហារកើនឡើង ដែលទាំងនេះធ្វើឱ្យប្រាក់ចំណូលពិតធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ដែលអាចគំរាមកំហែងជីវភាពរស់នៅរបស់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ ។ បាតុភាពនេះ គេឃើញច្បាស់តាមរយៈស្ថានភាពដែលគ្រួសារកម្ពុជាពាក់កណ្តាល បានកាត់បន្ថយការបរិភោគស្បៀងអាហារនៅឆ្នាំ២០០៨ ក្នុងអំឡុងពេលមានវិបត្តិថ្លៃស្បៀងអាហារ ។ ដោយសារមានចំណងទាក់ទងអន្តរជាតិ តាមរយៈពាណិជ្ជកម្ម និងថ្លៃ ការវិភាគពេញលេញអំពីផលប៉ះពាល់ក្នុងស្រុកដែលអាចកើតមានពីសំណាក់ការប្រែប្រួលអាកាសធាតុ ចាំបាច់ត្រូវពិចារណាអំពីផលប៉ះពាល់លើទ្រង់ទ្រាយទូទៅ ។

ការព្យាករណ៍អំពីសន្តិសុខស្បៀងដោយប្រើគំរូអន្តរជាតិសម្រាប់វិភាគគោលនយោបាយកសិកម្ម និងពាណិជ្ជកម្ម (IMPACT) បានព្យាករណ៍ថា ថ្លៃអន្តរជាតិនៃអង្ករ និងពោត នឹងឡើងខ្ពស់ ក្រោមសេណារីយ៉ូផ្សេងៗនៃការប្រែប្រួលអាកាសធាតុ ។ ថ្លៃពោតអន្តរជាតិ ងាយប្រែប្រួលទៅតាមសេណារីយ៉ូខុសៗគ្នាអំពីកំណើតប្រាក់ចំណូល និងប្រជាជន នៅលើពិភពលោក ប៉ុន្តែថ្លៃអង្ករអន្តរជាតិ ពុំសូវងាយប្រែប្រួលឡើយនៅក្នុងការសិក្សា ។ ទិន្នផលស្រូវ និងពោតក្នុងតំបន់មេគង្គខាងក្រោម (LMR) បានព្យាករណ៍ថា នឹងកើនឡើងយ៉ាងខ្ពស់ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០៥០ ។ តួលេខព្យាករណ៍អំពីទិន្នផលស្រូវ មានលក្ខណៈងាយប្រែប្រួលទៅតាមការប្រែប្រួលអាកាសធាតុជាងទិន្នផលពោត ។ ជាងនេះទៅទៀត លទ្ធផលនៃការសិក្សាបង្ហាញថា ទិន្នផលស្រូវ និងពោត ពុំមានលក្ខណៈងាយប្រែប្រួលខ្លាំង ទៅតាមសេណារីយ៉ូខុសៗគ្នានៃកំណើនប្រាក់ចំណូល ឬប្រជាជនឡើយ ដែលនេះគូសបញ្ជាក់ថា ការផ្គត់ផ្គង់មិនប្រែប្រួលឆាប់រហ័ស ឆ្លើយតបនឹងកំណើនថ្លៃនៅលើពិភពលោកដែលកាន់តែខ្ពស់ឡើយ ។ ផ្ទៃដីស្រូវដែលបានដាំដុះក្នុងតំបន់ដីគោកនៅអាស៊ីអាគ្នេយ៍ ត្រូវបានព្យាករណ៍ថា នឹងធ្លាក់ចុះពីឆ្នាំ២០១០ ដល់២០៥០ ហើយផ្ទៃដីដាំពោត ត្រូវបានព្យាករណ៍ថា ភាគច្រើនគ្មានការផ្លាស់ប្តូរឡើយ ។ ទាំងផ្ទៃដីដាំដុះដំណាំស្រូវ និងពោត មិនទំនងជាងាយប្រែប្រួល ចំពោះសេណារីយ៉ូខុសៗគ្នានៃការប្រែប្រួលអាកាសធាតុ ឬចំពោះសេណារីយ៉ូខុសៗគ្នានៃកំណើនសេដ្ឋកិច្ច ឬប្រជាជនឡើយ ។

លទ្ធផលរួមផ្សំនៃឥទ្ធិពលទិន្នផល និងផ្ទៃដី គឺផលិតកម្មពោតតំបន់ដីគោកនៅអាស៊ីអាគ្នេយ៍កើនឡើងនៅឆ្នាំ២០៥០ ដែលមកពីការពុំស្រូវប្រែប្រួលខ្លាំងទៅតាមការប្រែប្រួលអាកាសធាតុ ឬភាពខុសគ្នានៃកំណើនសេដ្ឋកិច្ច និងប្រជាជនឡើយ ។ ផលិតកម្មស្រូវមិនច្បាស់ថាកើន ឬថយចុះនៅក្នុងការសិក្សាឡើយ ហើយងាយប្រែប្រួលទៅតាមការប្រែប្រួលអាកាសធាតុ និងភាពខុសៗគ្នានៃកំណើនសេដ្ឋកិច្ច និងប្រជាជន ។ តំបន់ដីគោកនៅអាស៊ីអាគ្នេយ៍ទាំងមូលនាពេលបច្ចុប្បន្ននេះ គឺជាតំបន់នាំចេញអង្ករ និងពោត ។ ការព្យាករណ៍របស់យើង បង្ហាញថា តំបន់នេះនឹងបន្តជាតំបន់នាំចេញអង្ករ នៅក្រោមគ្រប់សេណារីយ៉ូនៃអាកាសធាតុ ប្រជាជន និងសេដ្ឋកិច្ចដែលបានប្រើប្រាស់ តំបន់នេះនឹងក្លាយទៅជាតំបន់នាំចូលពោតសុទ្ធនៅឆ្នាំ២០៥០ ។

ការព្យាករណ៍នៃគំរូ បង្ហាញថា អត្ថិភាពនៃស្បៀងអាហារក្នុងតំបន់ដីគោកនៅអាស៊ីអាគ្នេយ៍ នឹងកើនឡើងនៅក្រោមសេណារីយ៉ូនៃកំណើនសេដ្ឋកិច្ច និងប្រជាជន ដែលមានលក្ខណៈសុទិដ្ឋិនិយមកាន់តែខ្ពស់ ប៉ុន្តែធ្លាក់ចុះនៅក្នុងសេណារីយ៉ូទុទិដ្ឋិនិយម ។ ដូចគ្នាដែរ ចំនួនកុមារខ្វះអាហារូបត្ថម្ភនៅក្នុងតំបន់ នឹងថយចុះ ក្រោមសេណារីយ៉ូនៃកំណើនប្រជាជន និងកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈសុទិដ្ឋិនិយមកាន់តែខ្ពស់ ប៉ុន្តែថយចុះក្រោម

សេណារីយ៉ូទុទិដ្ឋិនិយម ។ ចំពោះករណីដែលបានពិនិត្យមើលទាំងអស់ ការប្រែប្រួលអាកាសធាតុ នឹងមានឥទ្ធិពលអវិជ្ជមានទៅលើសន្តិសុខស្បៀងនៅក្នុងតំបន់ ។

ជាផ្នែកមួយនៃការស្រាវជ្រាវទៅអនាគត នៅមានវិធីសាស្ត្រមួយចំនួនក្នុងការអនុវត្តគំរូ IMPACT ដើម្បីប៉ាន់ស្មានឱ្យបានកាន់តែប្រសើរ អំពីផលប៉ះពាល់ជាសក្តានុពលនៃការប្រែប្រួលអាកាសធាតុទៅលើវិស័យកសិកម្ម ពាណិជ្ជកម្ម និងសន្តិសុខស្បៀងនៅប្រទេសកម្ពុជា ។ នៅត្រង់នេះ យើងលើកចំណុចជាសក្តានុពលខ្លះៗសម្រាប់ការស្រាវជ្រាវនៅពេលអនាគត ។ ទីមួយ IMPACT អាចមានសារៈប្រយោជន៍សម្រាប់ការបង្កើតការព្យាករណ៍អំពីថាតើសេដ្ឋកិច្ចស្បៀងអាហារជាសាកល នឹងមានប្រតិកម្មចំពោះវិបត្តិខាងក្រៅជាក់លាក់យ៉ាងដូចម្តេច ។ រហូតដល់ពេលបច្ចុប្បន្ន គំរូនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើតេស្តអំពីផលប៉ះពាល់នៃការកែលម្អផលិតភាពពោតជាលក្ខណៈពាណិជ្ជកម្ម ការកែលម្អនៃផលិតភាពស្រូវសាលីនៅប្រទេសកំពុងអភិវឌ្ឍន៍ ការរាំងស្ងួតនៅតំបន់អាស៊ីខាងត្បូង ការកែលម្អជាសាកលនៃប្រសិទ្ធភាពអាងទឹក និងការផ្លាស់ប្តូរចំពោះគោលនយោបាយពាណិជ្ជកម្ម ។ ការពិសោធទាំងនេះ អាចមានសារៈប្រយោជន៍ក្នុងការពិនិត្យអំពីគោលនយោបាយពាក់ព័ន្ធនានាសម្រាប់ប្រទេសកម្ពុជា ដូចជា ការកែលម្អផលិតភាពស្រូវ ឬគោលនយោបាយហាមឃាត់ការនាំចេញស្រូវអង្ករ នៅពេលដែលស្បៀងអាហារសាកលឡើងថ្លៃ ។

លទ្ធភាពមួយទៀត គឺធ្វើឱ្យមានការផ្លាស់ប្តូរនៃផលិតភាពកសិកម្ម ដោយប្រើគំរូអាកាសធាតុក្នុងតំបន់ (Regional Climate Model-RCM) ដូចជាគំរូ PRECIS (Providing Regional Climates for Impacts Studies) ដែលបង្កើតឡើងដោយមជ្ឈមណ្ឌល Hadley សម្រាប់ការស្រាវជ្រាវ និងការព្យាករណ៍អំពីអាកាសធាតុ (Hadley Center for Climate Prediction and Research) ។ ចំពោះប្រទេសតូចដែលមានផ្ទៃដីតូចធៀបនឹងតំបន់ឆ្នេរ ការព្យាករណ៍អាកាសធាតុ ដោយ RCM ផ្តល់នូវដំណោះស្រាយកាន់តែប្រសើរ និងការព្យាករណ៍អំពីផលិតភាពដំណាំ មានលក្ខណៈកាន់តែប្រាកដប្រជា ជាងការព្យាករណ៍អាកាសធាតុ ដោយ GCM ។ ទោះបីជាបច្ចុប្បន្ននេះ IMPACT ជ្រើសប្រើ GCM ដើម្បីព្យាករណ៍ក៏ដោយ ប៉ុន្តែគេអាចមើលឃើញថា ត្រូវសម្របជាមួយនឹងការប្រើប្រាស់ RCM សម្រាប់ប្រទេសដែលមានចំណាប់អារម្មណ៍ ។

ប្រធានបទលំបាកមួយនៅក្នុងវិសាលភាពនៃការកសាងគំរូផ្នែកអាកាសធាតុ គឺវិធីសាស្ត្រដោះស្រាយចំពោះការផ្លាស់ប្តូរនៃបម្រែបម្រួលអាកាសធាតុ (variability in climate) ។ ថ្មីៗនេះ គំរូ IMPACT បានកែប្រែផលិតភាពដំណាំដែលទទួលបានពីការប្រែប្រួលរយៈពេលវែងនៃកម្រិតទឹកភ្លៀងមធ្យម និងការធ្លាក់ភ្លៀង ។ ប៉ុន្តែកង្វល់ជាច្រើនរបស់កម្ពុជាចំពោះភាពងាយរងគ្រោះនៃវិស័យកសិកម្ម ដោយសារការប្រែប្រួលអាកាសធាតុ គឺមានប្រភពមកពីការកើនឡើងនូវព្រឹត្តិការណ៍ធ្ងន់ធ្ងរផ្សេងៗ ដូចជា ភាពរាំងស្ងួត និងទឹកជំនន់ ។ អ្នករៀបចំ IMPACT បានលើកអំពីការដាក់បញ្ចូលព្រឹត្តិការណ៍ធ្ងន់ធ្ងរ និងការផ្លាស់ប្តូរនៃបម្រែបម្រួលធាតុអាកាស មកពិភាក្សាកាលពីពេលថ្មីៗនេះ ហើយការកែលម្អនេះ អាចមានសារៈប្រយោជន៍ខ្លាំង នៅក្នុងការបង្កើតព្យាករណ៍សម្រាប់បណ្តាប្រទេស ដូចជាកម្ពុជាជាដើម ដែលងាយប្រឈមមុខជាពិសេសទៅនឹងភាពរាំងស្ងួត និងទឹកជំនន់ ។

ចាំបាច់ត្រូវមានការសិក្សាបន្ថែម ដើម្បីកំណត់អំពីបណ្តាញនៃផលប៉ះពាល់ផ្សេងៗទៀត ដែលតាមបណ្តាញទាំងនេះ បម្រែបម្រួលអាកាសធាតុដែលមានស្រាប់ និងការប្រែប្រួលអាកាសធាតុរយៈពេលវែង អាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងពេលអនាគត ដែលរួមទាំងកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយការសិក្សានេះ ក៏ត្រូវវាយតម្លៃថាតើបណ្តាញនៃផលប៉ះពាល់ណាខ្លះ ដែលមានសារៈសំខាន់ក្នុងកសិកម្មកម្ពុជា ។ ដើម្បីអនុវត្តចំណុចនេះ ការប្រើប្រាស់វិធីសាស្ត្រវិភាគសេដ្ឋកិច្ចតាមបែប CGE (economy-wide general equilibrium model-CGE) អាចជាការចាំបាច់ ។ វិធីសាស្ត្រនេះ អាចវាយតម្លៃពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើថាមពល (រាប់ទាំងថាមពលវារីអគ្គិសនីផងដែរ) ហេដ្ឋារចនាសម្ព័ន្ធជនបទ និងតំបន់ឆ្នេរ (រាប់ទាំងផ្លូវថ្នល់) ព្រមទាំងវិស័យ

ដទៃទៀត ដែលងាយប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ និងមានសារៈសំខាន់សម្រាប់វិស័យកសិកម្ម (រួមមាន ជលផល បសុសត្វ និងកសិ-រុក្ខាកម្ម) ។ តាមរយៈការដាក់បញ្ចូលការព្យាករណ៍អំពីថ្លៃ និងទិន្នផល ពីគំរូ IMPACT គំរូ CGE អាចប៉ាន់ប្រមាណបានកាន់តែល្អអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ទៅលើសេដ្ឋកិច្ចក្នុងស្រុក តាមរយៈបណ្តាញទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ។ ការស្រាវជ្រាវទាំងនេះ មិនត្រឹមតែមានលក្ខណៈចាំបាច់ ដើម្បីស្វែងយល់អំពីទំហំនៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ គឺថែមទាំងមានប្រយោជន៍ សម្រាប់កសាងផែនការ វិនិយោគហេដ្ឋារចនាសម្ព័ន្ធនៅពេលអនាគត រួមមាន ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពថ្មីផងដែរ ។ ទោះបីជាការ ប្រែប្រួលអាកាសធាតុ ជាដំណើរការមួយមានរយៈពេលវែង និងប្រព្រឹត្តទៅជាបណ្តើរៗក៏ដោយ ក៏ត្រូវយកចិត្ត ទុកដាក់ទៅលើផលប៉ះពាល់ដែលបានសង្កេតឃើញពីព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរក្នុងពេលកន្លងមក (ទឹកជំនន់ រាំងស្ងួត និងខ្យល់ព្យុះ) ដោយសារព្រឹត្តិការណ៍ធ្ងន់ធ្ងរទាំងនេះ អាចកើនឡើងកាន់តែញឹកញាប់ ទន្ទឹមនឹងការ ប្រែប្រួលអាកាសធាតុ ។ ការរៀនសូត្រពីបទពិសោធន៍នៃការជម្នះលើព្រឹត្តិការណ៍ធ្ងន់ធ្ងរនានានៅកម្រិតសហគមន៍ ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ មានប្រយោជន៍សម្រាប់ការរៀបចំផែនការអនុវត្តជាក់ស្តែង និងអន្តរាគមន៍ជាគោល នយោបាយ ដែលលើកឡើងអំពីវិធានការកាត់បន្ថយ និងបន្សាំខ្លួន ។

## ការខ្វះចន្លោះផ្នែកចំណេះដឹង

នៅក្នុងសិក្ខាសាលា ក្រុមពិភាក្សាបានកំណត់នូវកង្វះចំណេះដឹងជាអាទិភាពចំនួនបី៖

១. ចំណងទាក់ទងរវាងការគ្រប់គ្រងធនធានធម្មជាតិ សន្តិសុខស្បៀង និងគោលនយោបាយសម្រាប់ការប្រែប្រួលអាកាសធាតុ

មន្ត្រីគោលនយោបាយ និងអ្នកពាក់ព័ន្ធគោលនយោបាយផ្សេងៗ ត្រូវយល់ដឹងកាន់តែច្បាស់ពីចំណងទាក់ទងរវាងការគ្រប់គ្រងធនធានធម្មជាតិ សន្តិសុខស្បៀង និងគោលនយោបាយសម្រាប់ការប្រែប្រួលអាកាសធាតុ ។ នេះគួរផ្តោតលើទស្សនៈវិស័យ ដែលឱ្យតម្លៃទៅលើប្រភពដែលកំពុងមាននៃភាពរឹងមាំនៃសកម្មភាពគ្រប់គ្រងធនធានធម្មជាតិ និងការអនុវត្តកសិកម្ម នៅជនបទកម្ពុជា និងថាតើសកម្មភាព និងការអនុវត្តទាំងនេះ អាចមានការគាំទ្រយ៉ាងដូចម្តេច ។

២. ជម្រើសសម្រាប់ការសម្របសម្រួលឆ្លងវិស័យសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ

ការអនុវត្តនូវគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិសមស្រប ដែលទ្រទ្រង់ដល់ការចិញ្ចឹមជីវិតនៅជនបទ និងសន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ តម្រូវឱ្យមានវិធីសាស្ត្រឆ្លងវិស័យ ដែលធ្វើសមាហរណកម្មនូវការគ្រប់គ្រងធនធានជលផល ដី ព្រៃឈើ និងទឹក ហើយក៏ត្រូវប្រើប្រាស់នូវឱកាសដែលមានដើម្បីពង្រឹងសមត្ថភាព និងប្រសិទ្ធភាពនៃស្ថាប័នក្នុងតំបន់ ក្រោមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ។ នេះទាមទារឱ្យមានការសម្របសម្រួលកាន់តែមានប្រសិទ្ធភាពរវាងក្រសួងជំនាញ ដោយភ្ជាប់វិស័យ ដូចជា ថាមពល ការអប់រំ កិច្ចការនារី និងអភិវឌ្ឍន៍ជនបទ បញ្ចូលគ្នា ។ មន្ត្រីគោលនយោបាយ និងអ្នកពាក់ព័ន្ធគោលនយោបាយ ចាំបាច់ត្រូវយល់ដឹងកាន់តែច្បាស់អំពីសកម្មភាពដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន ដើម្បីជួយដល់ការសម្របសម្រួលឆ្លងវិស័យ ព្រមទាំងត្រូវយល់ដឹងផងដែរពីវិធីដែលអាចជម្រុញឲ្យកិច្ចខិតខំទាំងនេះ កាន់តែមានប្រសិទ្ធភាព និងផ្សព្វផ្សាយទូលំទូលាយទៅថ្ងៃអនាគត ។

៣. ការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសមត្ថភាពក្នុងការស្រាវជ្រាវលើប្រធានបទនេះ

គណៈវិនិច្ឆ័យអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (the Intergovernmental Panel on Climate Change-IPCC) មានផ្តល់នូវគំរូអាកាសធាតុដែលបានធ្វើតេស្តរួចស្រាប់ (គំរូអាកាសធាតុពិភពលោក-GCMs) ជាច្រើន ដែលអាចយកមកប្រើប្រាស់បាន ។ ទោះបីជាគំរូទាំងនេះ មានលក្ខណៈជាក់លាក់តាមភូមិសាស្ត្រក៏ដោយ ក៏គំរូទាំងនេះមានទស្សនៈផ្សេងៗគ្នាអំពីកម្រិតនៃការផ្លាស់ប្តូរនៃសីតុណ្ហភាព និងសូម្បីតែទិសដៅនៃការផ្លាស់ប្តូរនៃកម្រិតទឹកភ្លៀង នៅតាមតំបន់ផ្សេងៗនៅប្រទេសកម្ពុជា (និងកន្លែងផ្សេងៗទៀត) ។ ស្ថានភាពនេះ បានបង្កើតជាភាពមិនប្រាកដប្រជាអំពីលទ្ធផលដែលយើងអាចសង្កេតឃើញនៅអនាគត ប៉ុន្តែយ៉ាងហោចណាស់ វាក៏បានកំណត់អំពីសារៈសំខាន់នៃភាពបត់បែន និងភាពរឹងមាំ ។

ទោះបីជាមានគំរូទាំងនេះ ហើយនាយកដ្ឋាននៃការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថានបានរៀបចំគំរូដំណាំសម្រាប់ធ្វើការវាយតម្លៃអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើដំណាំស្រូវក៏ដោយ ក៏កង្វះចំណេះដឹងនៅតែមាន ដូចជា ១) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើដំណាំផ្សេងៗ ជលផល និងព្រៃឈើ ក៏ដូចជាទៅលើធនធានធម្មជាតិផ្សេងៗទៀត ២) សមត្ថភាពស្រាវជ្រាវ ដើម្បីអភិវឌ្ឍគ្រាប់ពូជថ្មីៗ និងអភិវឌ្ឍ ឬអនុវត្តបច្ចេកទេសកសិកម្មឱ្យបានសមស្រប និង ៣) ការយល់ដឹងរបស់កសិករ ស្តីពីយុទ្ធសាស្ត្រជោគជ័យក្នុងការប្រើប្រាស់បច្ចេកទេសផ្សេងៗគ្នា ក្នុងការអនុវត្តកសិកម្មដែលចាំបាច់សម្រាប់ការសម្របទៅនឹងការប្រែប្រួលអាកាសធាតុ ។ កម្ពុជាមានបុគ្គលិកផ្សព្វផ្សាយកសិកម្ម ប៉ុន្តែទំនងជានៅមានគម្លាតរវាងចំនួនបុគ្គលិកដែលមាន និងចំនួនបុគ្គលិកដែលត្រូវការ ។

## អាទិភាពសម្រាប់ការស្រាវជ្រាវនាពេលអនាគត និងការកសាងសមត្ថភាព

១. តើអ្វីខ្លះជាគុណសម្បត្តិ និងហានិភ័យនៃសម្បទានសេដ្ឋកិច្ចខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មកសិកម្មខ្នាតតូច?

សម្បទានដីសេដ្ឋកិច្ចខ្នាតធំ (ELCs) ដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម ជារឿយៗ មិនបានផ្តល់នូវផលប្រយោជន៍ដូចបានសន្យា ដល់ប្រទេសកម្ពុជាឡើយ ។ ELCs តែងតែបង្កើតជាទំនាស់ជាមួយប្រជាជនមូលដ្ឋានស្តីពីសិទ្ធិប្រើប្រាស់ និងកម្មសិទ្ធិលើដីធ្លី ។ រដ្ឋាភិបាលប្រទេសជាច្រើន កំពុងធ្វើការចរចាយ៉ាងសកម្មលើកិច្ចព្រមព្រៀងរយៈពេលវែង ដើម្បីទទួលបានដីកសិកម្មនៅកម្ពុជា ប៉ុន្តែគេមិនច្បាស់ទេថា តើកិច្ចព្រមព្រៀងបែបនេះ អាចអនុវត្តយ៉ាងណាបាន ដោយពុំមានការជម្លៀសកសិករក្នុងមូលដ្ឋាន និងប្រជាជនដែលរស់នៅក្នុងព្រៃ ។ ប្រទេសដទៃទៀត បានទទួលជោគជ័យលើកិច្ចសន្យាកសិកម្ម និងគំរូផ្សេងៗដែលអនុញ្ញាតឱ្យផលិតករខ្នាតតូចនៅរក្សាកម្មសិទ្ធិលើដីធ្លីរបស់ពួកគេទន្ទឹមនឹងការទទួលផលប្រយោជន៍ពីការណែនាំជាលក្ខណៈបច្ចេកទេស ធាតុចូល ឥណទាន និងសេវាកម្មទីផ្សារពីគូអង្គវិស័យឯកជន ។ ការសិក្សាខ្លះ ក៏បានបង្ហាញផងដែរពីប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀតទាក់ទងនឹងសមធម៌ និងសន្តិសុខស្បៀង ។ ដូច្នេះត្រូវមានការវិភាគផ្តោតលើលទ្ធផលនៃសម្បទានខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ និងហានិភ័យនៃប្រព័ន្ធនីមួយៗ ភាពសមស្របរបស់វានៅក្នុងបរិបទខុសៗគ្នា និងប្រភេទនៃអន្តរាគមន៍ខាងគោលនយោបាយដែលត្រូវអនុវត្ត ។

២. តើអ្វីខ្លះជាជម្រើសជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានរួម ដោយផ្តោតទៅលើតួនាទីសំខាន់របស់វាសម្រាប់ការចិញ្ចឹមជីវិតនៅមូលដ្ឋាន?

ធនធានទ្រព្យរួម ដូចជា ព្រៃឈើ ដែននេសាទ តំបន់ដីសើម និងផ្ទៃទឹកនៅតាមតំបន់ឆ្នេរ ជាដើម មានសារៈសំខាន់បំផុតចំពោះជីវភាពប្រជាជនកម្ពុជាជាច្រើននៅតាមជនបទ ។ ប៉ុន្តែការរក្សាទុក និងធ្វើឱ្យមាន

និរន្តរភាពនូវទ្រព្យសម្បត្តិសាធារណៈសម្រាប់ការចិញ្ចឹមជីវិត និងសន្តិសុខស្បៀង ជារឿយៗ មិនមានការយកចិត្តទុកដាក់ ដូចដែលវាគួរទទួលបាន នៅក្នុងការអនុវត្តគោលនយោបាយឡើយ ។ ក្នុងទសវត្សរ៍កន្លងទៅនេះ មានការដាក់អនុវត្តកំណែទម្រង់ធំៗមួយចំនួន ជាពិសេសសកំណែទម្រង់ផលផលសហគមន៍ និងព្រៃឈើសហគមន៍ ដែលត្រូវបានរៀបចំឡើង ដើម្បីជម្រុញការគ្រប់គ្រងធនធានផ្អែកលើសហគមន៍ ។ ហើយឥឡូវដល់ពេលធ្វើការវាយតម្លៃពី ការផ្លាស់ប្តូរផ្សេងៗដែលកំណែទម្រង់ទាំងនោះបានបង្កចំពោះជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅមូលដ្ឋាន និងពីវិធានការផ្សេងៗទៀតដែលត្រូវប្រើដើម្បីកែលម្អការអនុវត្តគោលនយោបាយ ដោះស្រាយចំណុចខ្វះខាត និងពង្រីកអត្ថប្រយោជន៍នៃកំណែទម្រង់ទាំងនោះ ។

៣. តើវិធីសំខាន់បំផុតអ្វីខ្លះ ដែលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ពិសេសទំនប់ទឹក ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ) អាចធ្វើឱ្យខូចខាតដល់សេវាផ្អែកបរិស្ថាន? តើចំណុចនេះមានន័យយ៉ាងណាចំពោះការទ្រាំទ្រ និងសមត្ថភាពនៅកម្រិតមូលដ្ឋាន ក្នុងការបន្សាំជាមួយនឹងការប្រែប្រួលធាតុអាកាស និងនិន្នាការដទៃទៀត ដែលទំនងជាប៉ះពាល់ដល់សន្តិសុខស្បៀង? តើផលប៉ះពាល់ជាបន្តបន្ទាប់ទាំងនេះ ត្រូវបានវាស់ស្ទង់យ៉ាងដូចម្តេច ចំពោះផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងផលប្រយោជន៍សង្គមដែលបានរំពឹងទុក? តើតម្រូវការប្រជែងគ្នាទាំងនេះ ត្រូវបានសម្រុះសម្រួលគ្នាតាមវិធីណា ដើម្បីឱ្យមានប្រសិទ្ធភាព?

៤. តើអ្វីខ្លះអាចជាផលប្រយោជន៍ និងហានិភ័យនៃវិនិយោគក្នុងពេលអនាគតលើឧស្សាហកម្មនីស្សារណកម្ម ពិសេសប្រេងឥន្ធនៈ និងរ៉ែ? តើផលប្រយោជន៍ និងហានិភ័យទាំងនេះ ទំនងជាត្រូវបានបែងចែកយ៉ាងដូចម្តេច សម្រាប់សង្គមជាតិទាំងមូល? តើផលប្រយោជន៍ និងហានិភ័យទាំងនោះ មានផលប៉ះពាល់យ៉ាងដូចម្តេច មកលើឱកាសចិញ្ចឹមជីវិត និងនិន្នាការអភិវឌ្ឍន៍លើវិស័យកសិកម្ម ព្រៃឈើ និងជលផល? តើបទពិសោធន៍អន្តរជាតិល្អប្រសើរអ្វីខ្លះមានលក្ខណៈសមស្រប ដើម្បីណែនាំដល់ការសម្រេចចិត្តទាក់ទងនឹងវិនិយោគទាំងនេះ និងការគ្រប់គ្រងផលចំណូលពីធនធាន និងប្រាក់ចំណូលបានមកពីសកម្មភាពទាំងនេះ?

៥. តើយន្តការអ្វីខ្លះបានបង្ហាញឱ្យឃើញថា មានប្រសិទ្ធភាពបំផុតក្នុងការបង្កលក្ខណៈឱ្យមានភាពជាតំណាងប្រកបដោយសមធម៌ នៃប្រជាជនក្រីក្រ និងក្រុមពលរដ្ឋងាយរងគ្រោះ ក្នុងការសម្រេចចិត្តចំពោះកំណែទម្រង់គោលនយោបាយ និងស្ថាប័ន ក្នុងវិស័យធនធានធម្មជាតិ? តើមេរៀនអ្វីខ្លះបានពីបទពិសោធន៍អន្តរជាតិ ដែលអាចជួយពន្លឿនការដាក់បញ្ចូលអភិបាលកិច្ចធនធានធម្មជាតិទៅក្នុងសង្គមនៅកម្ពុជាផ្អែកលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយបច្ចុប្បន្ន?

៦. តើយន្តការអ្វីខ្លះ រួមទាំងយន្តការផ្លូវការ និងក្រៅផ្លូវការ ដែលមានលទ្ធភាពខ្ពស់បំផុតក្នុងការប្រឹងប្រែងលើកកម្ពស់គណនេយ្យភាពសាធារណៈ របស់អ្នកសម្រេចចិត្តនៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ ចំពោះសេចក្តីសម្រេចចិត្តនានាអំពីការបែងចែក និងគ្រប់គ្រងធនធានធម្មជាតិ? តើបណ្តាញ និងស្ថាប័នផ្សេងៗនៃសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ មានមុខងារអ្វីខ្លះចំពោះបញ្ហានេះ ហើយតើមុខងារទាំងនោះត្រូវបានពង្រឹងយ៉ាងដូចម្តេច?

៧. តើយុទ្ធសាស្ត្រអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុតក្នុងការកសាងស្ថាប័ន ដើម្បីឱ្យមានដំណោះស្រាយវិវាទ និងយុត្តិធម៌ ចំពោះប្រជាជនក្រីក្រដែលប្រើប្រាស់ធនធានធម្មជាតិ? តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ចំណងទាក់ទងរវាងតុលាការ រចនាសម្ព័ន្ធរដ្ឋបាល និងដំណើរការដោះស្រាយវិវាទក្រៅផ្លូវការ ដំណើរការដោះស្រាយវិវាទតាមបែបផ្សេង? តើមានមេរៀនអ្វីខ្លះអំពីបទពិសោធន៍អន្តរជាតិស្តីពីការផ្តោតជាសំខាន់ និងលំដាប់លំដោយនៃវិនិយោគនៅក្នុងទិដ្ឋភាពផ្សេងៗនៃដំណោះស្រាយវិវាទ?

៨. តើវិនិយោគអ្វីខ្លះទៅលើកិច្ចអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន ដែលមានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមស្តីពីការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍? តើធ្វើដូចម្តេចដើម្បីឱ្យគំនិតផ្តួចផ្តើមទាំងអស់នេះ អាចដាក់បញ្ចូលឱ្យបានល្អប្រសើរទៅក្នុងប្រព័ន្ធវិមជ្ឈការដែលត្រូវបានពង្រឹងកាលពីពេលថ្មីៗ សម្រាប់កសាងផែនការអភិវឌ្ឍន៍ជនបទ? តើឧបសគ្គអ្វីខ្លះដែលចាំបាច់ត្រូវដោះស្រាយដើម្បីឱ្យគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ បានទទួលលំហូរផលប្រយោជន៍កាន់តែល្អប្រសើរ?

៩. តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ការសម្រេចចិត្តចំពោះវិនិយោគរបស់វិស័យឯកជន? តើដំណើរការអ្វីខ្លះដែលមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ការប៉ាន់ប្រមាណអំពីគម្រោងនីមួយៗ ទៅកាន់ការវាយតម្លៃបែបយុទ្ធសាស្ត្រដែលមានលក្ខណៈទូលាយអំពីផលប្រយោជន៍ និងហានិភ័យ? តើយុទ្ធសាស្ត្រណាខ្លះ ដែលមានលទ្ធភាពខ្ពស់បំផុតក្នុងការជម្រុញអនុម័ត និងអនុវត្តន៍ស្តង់ដារ និងកិច្ចប្រតិបត្តិល្អប្រសើរជាលក្ខណៈអន្តរជាតិតាមវិស័យជាក់លាក់ ដើម្បីណែនាំដល់វិនិយោគផ្នែកកសិ-ឧស្សាហកម្ម រ៉ែ ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល?

១០. តើអាចធ្វើឱ្យមានតុល្យភាពរវាងហានិភ័យនៃការប្រែប្រួលអាកាសធាតុរយៈពេលវែង ជាមួយនឹងបញ្ហាប្រឈមបច្ចុប្បន្ននៃអភិបាលកិច្ចនិងការគ្រប់គ្រងធនធានធម្មជាតិ ដែរឬទេ? និន្នាការបម្រែបម្រួលអាកាសធាតុអាចបង្កជាហានិភ័យក្នុងរយៈពេលវែងក៏ពិតមែន ប៉ុន្តែការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនាពេលបច្ចុប្បន្ន វាចោទបញ្ហាបន្ទាន់ និងធ្ងន់ធ្ងរ ជាងដល់សន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រនៅកម្ពុជា ។ ទីភ្នាក់ងារជំនួយអន្តរជាតិដែលកំពុងផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការផ្តល់ហិរញ្ញប្បទានសម្រាប់ការសម្រាលឥទ្ធិពល និងការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុនោះ មិនគួរភ្លេចគិតគូរដល់បញ្ហាប្រឈមឯទៀតៗ ក្នុងការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនោះទេ ជាការសមស្របគួរមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយដែលផ្តោតលើហានិភ័យ និងឱកាស ដើម្បីបង្កើនលទ្ធភាពទប់ទល់ឧបសគ្គក្នុងការទ្រទ្រង់ជីវភាព និងលើកកម្ពស់សន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន ។

១១. វិនិយោគទៅលើសមត្ថភាពស្ថាប័នដើម្បីធ្វើការស្រាវជ្រាវអំពីការប្រែប្រួល អាកាសធាតុ តាមរយៈចំណងទាក់ទងកាន់តែប្រសើរជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិ ដូចជា IRRI ក៏ដូចជាកំណើនការគាំទ្រដល់ស្ថាប័នរដ្ឋ ដូចជា CARDI ។

១២. ការកំណត់អំពីគម្លាតនៃសេវាផ្សព្វផ្សាយកសិកម្ម និងការពង្រឹងសមត្ថភាពរបស់ ភ្នាក់ងារផ្សព្វផ្សាយ ។ នេះទំនងជាពាក់ព័ន្ធនឹងការបង្កើនចំនួនភ្នាក់ងារ បង្កើនការបណ្តុះបណ្តាល និងលើកកម្ពស់ចំណងទាក់ទងជាមួយស្ថាប័នស្រាវជ្រាវ ។ ការរកមើលពីផលចំណេញប្រកបដោយប្រសិទ្ធភាពដែលអាចទទួលបានតាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការផ្សព្វផ្សាយ និងអភិវឌ្ឍន៍បច្ចេកទេសកសិកម្ម ក៏ជាចំណុចសំខាន់មួយដែរ ។

## សន្និដ្ឋាន

កម្ពុជាទទួលជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន និងការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅអំឡុងពេលនៃកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ។ វិស័យកសិកម្ម គឺជាកត្តាជម្រុញដ៏សំខាន់បំផុតមួយសម្រាប់កំណើន និងបន្តដើរតួនាទីសំខាន់ក្នុងដំណើរការនៃការអភិវឌ្ឍនាពេលអនាគត ។ ប៉ុន្តែបញ្ហាប្រឈមនៅតែមានសម្រាប់កំណើនកសិកម្ម និងការលើកកម្ពស់អាហារូបត្ថម្ភ ។ ការកសាងសមត្ថភាព និងការស្រាវជ្រាវគោលនយោបាយ គួរផ្តោតលើការដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការផ្តល់នូវការវិភាគផ្អែកលើភស្តុតាងដែលអាចអនុវត្តរួមគ្នារវាងស្ថាប័នស្រាវជ្រាវ និងគោលនយោបាយក្នុងស្រុក និងអន្តរជាតិ ។ សេចក្តីសង្ខេបដែលមាននៅខាងលើ បង្ហាញអំពីវិស័យសក្តានុពលសម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវនាពេល

អនាគត ។ ផ្អែកលើលំហាត់បូកសរុប និងអនុសាសន៍ទទួលបានពីការពិភាក្សាជាក្រុមនៅក្នុងកិច្ចប្រជុំតុមូលអាទិភាពមួយចំនួនដូចខាងក្រោម ត្រូវបានលើកឡើងជាវិស័យសំខាន់សម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវគោលនយោបាយនៅពេលអនាគតដ៏ខ្លីខាងមុខ៖

១. ការគិតគូរឡើងវិញពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជានៅក្នុងផលិតកម្មស្រូវ ការកំណត់មាគ៌ាផ្សេងៗដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារស្រូវអង្ករអន្តរជាតិ និងការគិតគូរពី កម្លាំងគូបគ្នា និងផលចំណេញធៀបគ្នារវាងគោលដៅអភិវឌ្ឍន៍ខុសៗគ្នាក្នុងវិស័យស្រូវអង្ករ ។ តម្រូវការចាំបាច់ធ្វើការវាយតម្លៃពី ឥទ្ធិពលនៃគោលនយោបាយរបស់រដ្ឋាភិបាលសម្រាប់គាំទ្រវិស័យកសិកម្ម និងដំណាំជាក់លាក់មួយចំនួន មានជាអាទិ៍ ការវាយតម្លៃពីចំណាយ និងផល ចំណេញនៃវិនិយោគសាធារណៈ នៅក្នុងផែនការផ្សេងៗសម្រាប់អភិវឌ្ឍន៍ដំណាំស្រូវ ។ ម្យ៉ាងទៀតក្នុងការស្រាវជ្រាវពីមាគ៌ានានាសម្រាប់អភិវឌ្ឍន៍វិស័យស្រូវអង្ករ គេត្រូវតែពិចារណាពីផលប៉ះពាល់នៃយុទ្ធសាស្ត្រខុសៗគ្នាសម្រាប់អភិវឌ្ឍន៍វិស័យស្រូវអង្ករនេះ ទៅលើភាពក្រីក្រ សន្តិសុខស្បៀង និង អាហារូបត្ថម្ភ ទាំងនៅកម្រិតគ្រួសារ កម្រិតតំបន់ និងកម្រិតជាតិ ។

២. ការយល់ដឹងពីតម្រូវការទីផ្សារ ដោយកំណត់ឲ្យបាននូវទីផ្សារសម្រាប់នាំចេញស្រូវអង្ករ នាពេលបច្ចុប្បន្ន និងទៅអនាគត ។ ត្រូវមានការស្រាវជ្រាវស៊ីជម្រៅ ដើម្បីញែកទីផ្សារផ្សេងៗឲ្យច្បាស់ ក្នុងនេះមានទាំងការពង្រីកទីផ្សារមានស្រាប់ និងការស្វែងរកទីផ្សារថ្មី និងទីផ្សារពិសេសៗ ។ ការសិក្សាពីឧបសគ្គចំបងៗក្នុងការពង្រីក និងជ្រៀតចូលទីផ្សារ ព្រមទាំង គោលនយោបាយសម្រាប់ដោះស្រាយឧបសគ្គទាំងនេះ ក៏ត្រូវធ្វើឡើងដែរ ។ ការស្រាវជ្រាវក៏ត្រូវគូសបញ្ជាក់អំពី ឥទ្ធិពលកាត់កងគ្នារវាងការនាំចេញអង្ករ នឹងការផ្គត់ផ្គង់ស្បៀងក្នុងប្រទេស ព្រមទាំងគោលនយោបាយត្រូវអនុវត្តដើម្បីរក្សាតុល្យភាពល្អរវាងតម្រូវការ និងការនាំចេញ ។

៣. ការវាយតម្លៃពីជម្រើសផ្សេងៗសម្រាប់ពិពិធកម្មកសិកម្ម ដោយយកចិត្តទុកដាក់លើបទពិសោធន៍ និងមេរៀនដែលប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ធ្លាប់ឆ្លងកាត់ ។ ការស្រាវជ្រាវនេះគួរផ្តោតលើទាំងផលិតកម្ម និងពិពិធកម្មការប្រើប្រាស់ ពីព្រោះបទពិសោធន៍នៅប្រទេសអាស៊ីអាគ្នេយ៍ឯទៀតៗបានបង្ហាញថា ពិពិធកម្មផលិតកម្មស្បៀងអាហារ អាចនាំឲ្យមានពិពិធកម្មការប្រើប្រាស់ដែលតែងជួយកែលម្អស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារនៅជនបទ ។ ទំនាក់ទំនងរវាងពិពិធកម្មផលិតកម្ម ពិពិធកម្មការប្រើប្រាស់ និងភាពប្រសើរឡើងនៃអាហារូបត្ថម្ភ គួរទទួលបានការសិក្សាលម្អិតជាងនេះទៅថ្ងៃអនាគត ។

៤. ការវិភាគពីមូលហេតុនៃអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ការយកចិត្តទុកដាក់ជាពិសេសលើលំនាំចំណាយលើម្ហូបអាហារ ការប្រើប្រាស់ស្បៀងអាហារ និងទម្លាប់ប្រើប្រាស់ស្បៀងអាហាររបស់ប្រជាជន ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធផលិតកម្មកសិកម្ម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។ ផលប៉ះពាល់ខាងអាហារូបត្ថម្ភ និងសន្តិសុខស្បៀង នៃអន្តរាគមន៍ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដូចជា ការសាងសង់ទំនប់ទប់ស្ទឹងទន្លេ ជាដើម ហើយនិងការប៉ះទង្គិចផ្សេងៗពីខាងក្រៅ ក៏គួរគិតគូរពិចារណាក្នុងការស្រាវជ្រាវដែរ ។

៥. ការបង្កើតជាវេទិកាមួយសម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យ ដើម្បីវាយតម្លៃកម្មវិធីគាំពារសង្គម ។ សកម្មភាពនេះត្រូវមាន ឧបករណ៍សមស្របជាក់ស្តែងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីគាំពារសង្គមដែលមានស្រាប់ ដើម្បីពង្រីកបន្ថែមកម្មវិធីដែលបានជោគជ័យ រចនារៀបចំកម្មវិធីឲ្យបានកាន់តែប្រសើរឡើងទៀត និងផ្តោតអន្តរាគមន៍ឲ្យកាន់តែចំគោលដៅនាពេលអនាគត ។

៦. ការវិភាគពីការបំពេញបន្ថែមគ្នា និងការជម្រើសរវាង គ្រោះថ្នាក់នៃហានិភ័យបម្រែបម្រួលអាកាសធាតុក្នុងរយៈពេលវែង និងបញ្ហាប្រឈមបច្ចុប្បន្នក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ និន្នាការបម្រែបម្រួល

អាកាសធាតុអាចបង្កជាហានិភ័យក្នុងរយៈពេលវែងក៏ពិតមែន ប៉ុន្តែការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនាពេលបច្ចុប្បន្ន វាចោទបញ្ហាបន្ទាន់ និងធ្ងន់ធ្ងរជាងដល់សន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រនៅកម្ពុជា ។ អន្តរាគមន៍ផ្នែកសន្តិសុខស្បៀងនៅកម្ពុជា ត្រូវឆ្លើយតបនឹងហានិភ័យ និងឱកាសល្អច្រើនបែបយ៉ាង ។ ទីភ្នាក់ងារជំនួយអន្តរជាតិដែលកំពុងផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការផ្តល់ហិរញ្ញប្បទានសម្រាប់ការសម្រាលឥទ្ធិពល និងការបន្សាំខ្លួនទៅនឹង បម្រែបម្រួលអាកាសធាតុនោះ មិនគួរភ្លេចគិតគូរដល់បញ្ហាប្រឈមឯទៀតៗ ក្នុងការគ្រប់គ្រង និងអភិបាលកិច្ចធនធានធម្មជាតិនោះទេ ។ ជាការសមស្រប គួរមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយដែលផ្តោតលើហានិភ័យ និងឱកាស ដើម្បីបង្កើនលទ្ធភាពទប់ទល់ឧបសគ្គក្នុងការទ្រទ្រង់ជីវភាព និងលើកកម្ពស់សន្តិសុខស្បៀងនៅកម្រិតមូលដ្ឋាន ។

៧. ការវិភាគពីផលចំណេញ និងហានិភ័យនៃសម្បទានខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មខ្នាតតូច ។ សម្បទានដីសេដ្ឋកិច្ចខ្នាតធំ (ELCs) ដែលសំដៅជម្រុញការអភិវឌ្ឍកសិឧស្សាហកម្ម មិនបានជោគជ័យទេក្នុងការផ្តល់អត្ថប្រយោជន៍តាមការសន្យា ដល់ប្រទេសកម្ពុជា ។ រដ្ឋាភិបាលប្រទេសជាច្រើនកំពុងធ្វើការចរចាយ៉ាងសកម្មលើកិច្ចព្រមព្រៀងរយៈពេលវែង ដើម្បីទទួលបានដីកសិកម្មនៅកម្ពុជា ប៉ុន្តែគេមិនច្បាស់ទេថាតើកិច្ចព្រមព្រៀងបែបនេះ អាចអនុវត្តយ៉ាងណាបាន ដោយពុំមានការជម្លៀសកសិករក្នុងមូលដ្ឋាន និងប្រជាជនដែលរស់នៅក្នុងព្រៃ ។ ការសិក្សាខ្លះ ក៏បានបង្ហាញផងដែរពី ប្រសិទ្ធភាពខាងសេដ្ឋកិច្ចនៃផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀតទាក់ទងនឹងសមធម៌ និងសន្តិសុខស្បៀង ។ ដូច្នេះត្រូវមានការវិភាគផ្តោតលើលទ្ធផលនៃសម្បទានខ្នាតធំ ធៀបនឹងប្រព័ន្ធផលិតកម្មខ្នាតតូច ព្រមទាំងអត្ថប្រយោជន៍ និងហានិភ័យនៃប្រព័ន្ធនីមួយៗ ភាពសមស្របរបស់វានៅក្នុងបរិបទខុសៗគ្នា និងប្រភេទនៃអន្តរាគមន៍ខាងគោលនយោបាយដែលត្រូវអនុវត្ត ។

៨. ការស្រាវជ្រាវពីយុទ្ធសាស្ត្រថ្នាក់ជាតិមួយសម្រាប់គ្រប់គ្រងធនធានទ្រព្យរួម ដោយផ្តោតលើតួនាទីធនធានទាំងនោះសម្រាប់ជីវភាពនៅមូលដ្ឋាន ។ ធនធានទ្រព្យរួម ដូចជា ព្រៃឈើ ដែននេសាទ តំបន់ដីសើម និងផ្ទៃទឹកនៅតាមតំបន់ឆ្នេរ ជាដើម មានសារៈសំខាន់បំផុតចំពោះជីវភាពប្រជាជនកម្ពុជាជាច្រើននៅតាមជនបទ ។ ក្នុងទសវត្សរ៍កន្លងទៅនេះ មានការដាក់អនុវត្តកំណែទម្រង់ធំៗមួយចំនួន ហើយឥឡូវដល់ពេលធ្វើការវាយតម្លៃពី ការផ្លាស់ប្តូរផ្សេងៗដែលកំណែទម្រង់ទាំងនោះបានជះឥទ្ធិពលចំពោះជីវភាពរស់នៅ និងសន្តិសុខស្បៀងនៅមូលដ្ឋាន និងពីវិធានការផ្សេងៗទៀតដែលត្រូវប្រើដើម្បីកែលម្អការអនុវត្តគោលនយោបាយ ដោះស្រាយចំណុចខ្វះខាត និងពង្រីកអត្ថប្រយោជន៍នៃកំណែទម្រង់ទាំងនោះ ។

៩. ការស្រាវជ្រាវអំពីយុទ្ធសាស្ត្រផ្សេងៗទៀតសម្រាប់ជួយកសិករទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ ក្នុងនេះមានទាំងអនុសាសន៍សម្រាប់ការផ្លាស់ប្តូរគោលនយោបាយ និងអនុសាសន៍ស្តីពីដំណាំថ្មីៗ ប្រភេទរុក្ខជាតិសម្រាប់ដាំដុះ និងបច្ចេកទេសដាំដុះ ។ ការស្រាវជ្រាវនេះក៏ត្រូវស្វែងរកមើលនូវចំណុចខ្វះខាតក្នុងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក្នុងស្ថានភាពកំពុងមានបម្រែបម្រួលអាកាសធាតុ និងអន្តរាគមន៍ផ្សេងៗទៀត ដើម្បីពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។ ការស្រាវជ្រាវពីបម្រែបម្រួលអាកាសធាតុ មិនគួរមានតែអង្គការអន្តរជាតិជាអ្នកអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើវិនិយោគជាបន្ទាន់កសាងសមត្ថភាពស្ថាប័នក្នុងស្រុក ដើម្បីធ្វើការស្រាវជ្រាវប្រភេទនេះ ។ ម្យ៉ាងទៀត ក៏គួរមានចំណងទាក់ទងកាន់តែប្រសើរឡើងរវាងស្ថាប័នខាងបម្រែបម្រួលអាកាសធាតុរបស់រដ្ឋាភិបាល និងមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនានា និងគួរបង្កើនជំនួយគាំទ្រដល់ស្ថាប័នជាតិផងដែរ ។

១០. ការស្រាវជ្រាវអំពីការវាយតម្លៃផលប៉ះពាល់ខាងផ្លូវច្បាប់ (Regulatory Impact Assessment-RIA) ដើម្បីវាយតម្លៃអំពីផលប៉ះពាល់ និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ។ ការស្រាវជ្រាវនេះ អាចអនុវត្តបានសម្រាប់គោលនយោបាយនៅគ្រប់កម្រិតទាំងអស់ ។

## ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ ១. ឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំតុមូល

ថេង វុទ្ធី និង កុយ រ៉ា (CDRI)៖ ការពិនិត្យត្រួសៗពីគោលនយោបាយកសិកម្ម និង ការស្រាវជ្រាវគោលនយោបាយ

Bingxin Yu និង Xinshen Dial (IFPRI)៖ យុទ្ធសាស្ត្រវិស័យកសិកម្មនៅកម្ពុជា៖ ជម្រើសអភិវឌ្ឍន៍នៅពេលអនាគតសម្រាប់វិស័យស្រូវ

Olivier Ecker និង Xinshen Diao (IFPRI)៖ សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា៖ លំនាំ និង មាគ៌ាឆ្ពោះទៅរកជោគជ័យ

គឹម សុធន (CDRI)៖ ជម្រើសគោលនយោបាយសម្រាប់ក្រុមជនងាយរងគ្រោះ ៖ កំណើនប្រាក់ចំណូលនិងការគាំពារសង្គម

Blake D. Ratner (IFPRI)៖ អភិបាលកិច្ចធនធានធម្មជាតិ និង សន្តិសុខស្បៀងនៅកម្ពុជា

Timothy S. Thomas និង Nicholas Magnan (IFPRI)៖ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុដល់ឆ្នាំ២០៥០៖ ប្រទេសកម្ពុជា

### ឧបសម្ព័ន្ធ ២. បទបង្ហាញនៅក្នុងកិច្ចប្រជុំតុមូល

### ឧបសម្ព័ន្ធ ៣. បញ្ជីអ្នកចូលរួម